ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
Ministry of Foreign Affairs
and International Cooperation

# យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច
# ឆ្នាំ២០២១-២០២៣



# យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច
# ឆ្នាំ២០២១-២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ ៥៧០ កបទ.សអ

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ និងបំពេញបន្ថែមមាត្រា៣៤ថ្មីស្ទួន និងមាត្រា៣៩ស្ទួន របស់អនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ



អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

- បានឃើញសេចក្តីសម្រេចលេខ ២៧២ កបទ.សអ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញសេចក្តីសម្រេចលេខ ៧៨៤ កបទ.សអ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមការចាំបាច់របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**ប្រការ ១._**

ត្រូវបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ ដូចមានភ្ជាប់មកជាមួយប្រកាសនេះ។

**ប្រការ ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអង្គភាពចំណុះទីស្តីការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស ។

**ប្រការ ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង និងប្រធានគ្រប់ស្ថានតំណាងកម្ពុជានៅបរទេសត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២០

**រដ្ឋមន្ត្រី**

**ប្រាក់ សុខុន**

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ

# មាតិកា

**សេចក្តីផ្តើម** ........ ១
១. ទិដ្ឋភាពទូទៅ ........ ១
២. បរិបទជាតិ ........ ៣
៣. ការទូតសេដ្ឋកិច្ចកម្ពុជា ........ ៦
**ជំពូកទី១ - ការទូតសេដ្ឋកិច្ច** ........ ៧
១. ចក្ខុវិស័យ និងបេសកកម្ម ........ ៧
២. គោលបំណងនៃយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ........ ៨
៣. គោលដៅនៃយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ........ ៨
៤. អភិក្រម ........ ៨
៥. ក្របខ័ណ្ឌគោលនយោបាយ ........ ៨
៥.១. វិសាលភាពការងារការទូតសេដ្ឋកិច្ច ........ ៨
៥.២. ក្របខ័ណ្ឌសកម្មភាពការងារការទូតសេដ្ឋកិច្ច ........ ៩
៥.៣. ស្ថាប័នទទួលខុសត្រូវ ........ ១១
៥.៤. បញ្ហាប្រឈម ........ ១១
**ជំពូកទី២ - យុទ្ធសាស្ត្រ** ........ ១២
១. ការកសាងធនធានមនុស្ស ........ ១២
២. ការលើកកម្ពស់យន្តការទំនាក់ទំនង និងចែករំលែកព័ត៌មាន ........ ១២
៣. ការលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ........ ១៣
**ជំពូកទី៣ - ផែនការសកម្មភាពរួមតាមដំណាក់កាល** ........ ១៤
១. ដំណាក់កាលទី១៖ ឆ្នាំ២០២១ ........ ១៤
២. ដំណាក់កាលទី២៖ ឆ្នាំ២០២២ ........ ១៤
៣. ដំណាក់កាលទី៣៖ ឆ្នាំ២០២៣ ........ ១៤
**ជំពូកទី៤ - ធនធានហិរញ្ញវត្ថុ** ........ ១៥
១. តម្រូវការថវិកា ........ ១៥
២. ប្រភពថវិកា ........ ១៥

**ជំពូកទី៥ - ការតាមដាន និងវាយតម្លៃ** ........ ១៥
**សេចក្តីសន្និដ្ឋាន** ........ ១៦
**ឧបសម្ព័ន្ធ** ........ ១៨
ឧបសម្ព័ន្ធទី១ ៖ ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២១-២០២៣........ ១៨
ឧបសម្ព័ន្ធទី២ ៖ អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ........ ៣៩
ឧបសម្ព័ន្ធទី៣ ៖ សេចក្តីសម្រេច ស្តីពីការការបង្កើតក្រុមការងារសម្របសម្រួល ការទូតសេដ្ឋកិច្ច........ ៥៩
ឧបសម្ព័ន្ធទី៤ ៖ សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពក្រុមការងារ សម្របសម្រួលការទូតសេដ្ឋកិច្ច........ ៦៤

# សេចក្ដីផ្ដើម

## ១. ទិដ្ឋភាពទូទៅ

ជាងមួយទសវត្សរ៍បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨ សេដ្ឋកិច្ចពិភពលោក និងប្រព័ន្ធពាណិជ្ជកម្មពហុភាគីសកលលោក កំពុងស្ថិតនៅក្រោមសម្ពាធដ៏ធ្ងន់ធ្ងរសាជាថ្មីម្ដងទៀត ដោយសារការកើនឡើងនូវការគាំពារ និងឯកតោភាគីនិយម។ ជាមួយគ្នានេះដែរ ការរីករាលដាលនៃជំងឺរាតត្បាតសកលកូវីដ-១៩ គឺជាកត្តាចម្បងមួយដែលនាំមកនូវការប្រែប្រួលជាអចិន្ត្រៃយ៍នៃសណ្ដាប់ធ្នាប់សេដ្ឋកិច្ចពិភពលោក។

កត្តាធំពីរដែលធ្វើឱ្យពិភពលោកយើងទាំងមូលប្រឈមនឹងការគំរាមកំហែងធ្ងន់ធ្ងរមិនធ្លាប់ជួបក្នុងរយៈពេលជាងបីទសវត្សរ៍ចុងក្រោយនេះ គឺកត្តាធម្មជាតិ និងកត្តាមនុស្ស។ ក្នុងចំណោមកត្តាធម្មជាតិទាំងឡាយ ជំងឺឆ្លងកូវីដ-១៩ គឺជាកត្តាមួយដែលមិនត្រឹមតែប៉ះពាល់ខ្លាំងក្លាដល់វិស័យសុខាភិបាលប៉ុណ្ណោះទេ វាក៏បណ្ដាលឱ្យសេដ្ឋកិច្ចពិភពលោកទាំងមូលធ្លាក់ក្នុងវិបត្តិយ៉ាងជ្រាលជ្រៅ និងបានរុញឱ្យខ្សែចង្វាក់ផ្គត់ផ្គង់តំបន់ និងពិភពលោករអាក់រអួល និងកាត់ផ្ដាច់ក្នុងកម្រិតធ្ងន់ធ្ងរ។ វិស័យទេសចរណ៍បានធ្លាក់ចុះដល់កម្រិតដែលមិនធ្លាប់មានពីមុនមក។ វិស័យដឹកជញ្ជូន ជាពិសេសផ្លូវអាកាសបានគាំងដំណើរការ ចំណែកឯទំនុកចិត្តខាងធុរកិច្ច និងអតិថិជនបានធ្លាក់ចុះដោយសារវិធានការរឹតត្បិតនានាដើម្បីទប់ស្កាត់ការរីករាលដាលជំងឺឆ្លងកូវីដ-១៩។ ជំងឺនេះក៏បាននឹងកំពុងបង្កហានិភ័យនៃការក្ស័យធនផ្នែកធុរកិច្ចកាន់តែធំឡើង និងការបាត់បង់ការងាររបស់មនុស្សរាប់រយលាននាក់។ ផលប៉ះពាល់របស់កូវីដ-១៩ មិនត្រឹមតែលាតសន្ធឹងលើវិស័យសេដ្ឋកិច្ច-សង្គម និងហិរញ្ញវត្ថុប៉ុណ្ណោះទេ តែក៏បានរាលដាលហាក់ចូលក្នុងសង្វៀននយោបាយដោយការធ្វើនយោបាយតូបនីយកម្មផងដែរ។

កត្តាមនុស្សបាននឹងកំពុងធ្វើឱ្យស្ថិរភាព និងវិបុលភាពរយៈពេលជាង៧០ឆ្នាំ ដែលកើតចេញពីសណ្ដាប់ធ្នាប់អន្តរជាតិផ្អែកលើពហុប៉ូលនិយម និងច្បាប់អន្តរជាតិនោះទទួលរងភាពរង្គោះរង្គើយ៉ាងខ្លាំង។ ទាំងនេះក៏ដោយសារការរំលោភបំពាន ការលែងគោរពនូវគុណតម្លៃមួយចំនួនដែលជាមូលដ្ឋានគ្រឹះនៃសណ្ដាប់ធ្នាប់ ការងាកទៅរកឯកតោភាគីនិយម និងការប្រើកម្លាំងគាបសង្កត់ប្រទេសទន់ខ្សោយ។ល។ លើសពីនេះទៅទៀត ការប្រកួតប្រជែងគ្នាខាងភូមិសាស្ត្រនយោបាយ និងយុទ្ធសាស្ត្រដ៏តានតឹងរវាងមហាអំណាចធំបំផុតទាំងពីរ កំពុងឈានទៅរកសង្គ្រាមត្រជាក់បែបថ្មី ដែលធ្វើឱ្យមានការ

ផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅ ឆាប់រហ័ស ពិបាកប៉ាន់ស្មាន និងប្រកបដោយគ្រោះថ្នាក់បំផុត។ ការបង្កសង្គ្រាមពាណិជ្ជកម្មនេះ បានធ្វើឱ្យរីករាលដាលដល់សមរភូមិផ្សេងទៀតដូចជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា យោធា ចារកម្ម សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងមនោគមវិជ្ជា។ ការប្រជែងឥទ្ធិពល និងអំណាចនេះ បានបង្កនូវការលំបាក ការប្រឈម និងកង្វល់ស្មុគស្មាញដល់ប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងកម្ពុជាផងដែរ ទាំងក្នុងផ្នែកនយោបាយ និងសេដ្ឋកិច្ច ជាពិសេសការរួមបញ្ចូលបញ្ហាទាំងពីរក្នុងពេលតែមួយដូចដែលគេបានអនុវត្តមកលើកម្ពុជានាពេលកន្លងមក ដោយអនុវត្តស្តង់ដារពីរពាក់ព័ន្ធបញ្ហាសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ជាមួយនឹងការដករបបអនុគ្រោះពន្ធក្រោមប្រព័ន្ធ Everything but Arms (EBA) ចំនួន២០%។

ក្រោមទិដ្ឋភាពភូមិសាស្ត្រសេដ្ឋកិច្ចវិញ ប្រព័ន្ធសេដ្ឋកិច្ចដែលមានការផ្សារភ្ជាប់គ្នាទៅវិញទៅមក គឺជាប្រព័ន្ធដែលមានលក្ខណៈផុយស្រួយដោយមូលហេតុថា សកលភាវូបនីយកម្មសេដ្ឋកិច្ចបានដើរលឿនជាងសកលភាវូបនីយកម្មនយោបាយ។ ហេតុនេះរដ្ឋនីមួយៗបានពិចារណាឡើងវិញអំពីកម្រិតនៃភាពបើកចំហរបស់ប្រទេសខ្លួន ចំពោះសេដ្ឋកិច្ចពិភពលោក ដើម្បីរក្សាបាននូវឯករាជ្យភាព និងអធិបតេយ្យភាពនៅក្នុងកម្រិតណាមួយ ជាពិសេសក្នុងអំឡុងពេលមានវិបត្តិ។ ម្យ៉ាងវិញទៀត តួនាទីរបស់ប្រព័ន្ធឌីជីថលូបនីយកម្ម និងការរីកចម្រើនបច្ចេកវិទ្យា កាន់តែមានសារៈសំខាន់នៅខណៈពេលដែលសកលភាវូបនីយកម្មកំពុងទទួលរងនូវសម្ពាធដោយសារតែការកើនឡើងនូវផ្នត់គំនិតជាតិនិយមជ្រុល និងការគាំពារនិយម។ ហេតុដូចនេះ រដ្ឋាភិបាលនៃប្រទេសនីមួយៗចាំបាច់ត្រូវដើរតួនាទីកាន់តែសកម្មជាងមុន ដើម្បីកសាងភាពជាដៃគូអន្តរជាតិសម្រាប់កំណើនសេដ្ឋកិច្ច ធានាបាននូវភាពរឹងមាំ និងសមត្ថភាពរបស់រដ្ឋក្នុងការស្តារឡើងវិញពីគ្រោះមហន្តរាយនេះប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព។

ជាការពិតណាស់ ប្រសិនបើគ្មានសាមគ្គីភាពក្នុងការដឹកនាំ និងកិច្ចខិតខំប្រឹងប្រែងរួមកម្រិតពិភពលោកនោះទេ ការស្តារឡើងវិញនៃសេដ្ឋកិច្ច គឺប្រាកដជាមានភាពយឺតយ៉ាវមិនច្បាស់លាស់ ខណៈដែលឱនភាពសេដ្ឋកិច្ចនឹងនៅតែបន្តជាបញ្ហាប្រឈម និងអាចកាន់តែមានសភាពធ្ងន់ធ្ងរ។ មានការរំពឹងថា ផលប៉ះពាល់អវិជ្ជមានមកលើសេដ្ឋកិច្ចពិភពលោកអាចនឹងបន្តប៉ុន្មានឆ្នាំទៅមុខទៀត ស្របពេលដែលប្រទេសជាច្រើននៅលើពិភពលោកកំពុងប្រឈមនឹងហានិភ័យ និងផលប៉ះពាល់អវិជ្ជមានទាំងនេះ។ ប្រទេសកំពុងអភិវឌ្ឍន៍ គឺជាប្រទេសដែលងាយរងគ្រោះជាងគេពីការផ្លាស់ប្តូរ និងភាពមិនប្រាកដ

ប្រជាទាំងនេះ ដោយសារកង្វះធនធានក្នុងការទប់ទល់វិបត្តិរចនាសម្ព័ន្ធ និងមធ្យោបាយកាត់បន្ថយហានិភ័យផ្សេងៗបានដោយខ្លួនឯង ខណៈពេលដែលប្រទេសទាំងនោះកំពុងខិតខំធ្វើសមាហរណកម្មខ្លួនយ៉ាងសកម្មទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។

នៅក្នុងបរិបទនេះ ប្រទេសកំពុងអភិវឌ្ឍន៍ចាំបាច់ត្រូវតែប្រឹងសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ កសាងលទ្ធភាព និងសមត្ថភាពខ្លួន ដើម្បីបញ្ចៀសពីហានិភ័យទាំងឡាយតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការជំរុញពាណិជ្ជកម្ម និងវិនិយោគ ការអភិវឌ្ឍកសិ-ឧស្សាហកម្ម និងទេសចរណ៍ប្រកបដោយនវានុវត្តន៍។ ជាងនេះទៅទៀត ប្រទេសទាំងនោះចាំបាច់ត្រូវពង្រឹង និងស្តារកំណើនសេដ្ឋកិច្ចឡើងវិញតាមរយៈ ការនាំចេញ ការធ្វើកំណែទម្រង់បណ្តាញទាក់ទាញវិនិយោគផ្ទាល់ពីបរទេស ការកែច្នៃផលិតផល និងសេវាកម្មទេសចរណ៍ ការពង្រឹងធនធានមនុស្ស ការអភិវឌ្ឍ និងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងការលើកកម្ពស់ការចូលរួមពីវិស័យឯកជន ដើម្បីទាញយកអត្ថប្រយោជន៍ពីបដិវត្តន៍ឧស្សាហកម្មទី៤។

ក្នុងន័យនេះ «**ការទូតសេដ្ឋកិច្ច**» គឺជាឧបករណ៍ដ៏សំខាន់មួយសម្រាប់រដ្ឋាភិបាលក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងពិភពលោកតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីឱ្យកាន់តែស៊ីជម្រៅ និងទូលំទូលាយ ដើម្បីធ្វើពិពិធកម្មប្រភពកំណើនរបស់ខ្លួន ពង្រីកសក្តានុពលសេដ្ឋកិច្ច និងទាញយកអត្ថប្រយោជន៍ពេញលេញពីកាលានុវត្តភាពថ្មីៗ។ យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចត្រូវមានលក្ខណៈមុតស្រួច និងវាងវៃក្នុងការការពារ និងធានាបាននូវការលើកកម្ពស់ផលប្រយោជន៍ជាតិនៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ ដើម្បីឆ្ពោះទៅកាន់វិបុលភាពផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។

## ២. បរិបទជាតិ

ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កម្ពុជាបានប្រែក្លាយពីប្រទេសមួយដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម និងរងទុក្ខវេទនាដែលមិនអាចគណនាបាន ទៅជាប្រទេសដែលមានការរីកចម្រើនប្រកបដោយថាមភាព មានការអភិវឌ្ឍសង្គមលើគ្រប់វិស័យ ការគោរពលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងសិទ្ធិមនុស្ស។ ការបង្រួបបង្រួមជាតិក្រោមគោលនយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងកំណែទម្រង់ទីផ្សារសេរីគឺឈប់ឈរ បានពង្រឹងមូលដ្ឋានគ្រឹះ

សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលជាង៣ទសវត្សរ៍កន្លងមកនេះ។ ជាលទ្ធផល កម្ពុជាបានកសាងសន្តិភាព ស្ថិរភាពនយោបាយ និងរក្សាបានលំនឹងម៉ាក្រូសេដ្ឋកិច្ច ជាមួយនឹងកំណើនជាមធ្យមជាង៧%ក្នុងមួយឆ្នាំ (១៩៩៨ ដល់២០១៩) ដោយបានប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥។ ទន្ទឹមនេះនៅឆ្នាំ២០១៦ កម្ពុជាត្រូវបានសហគមន៍អន្តរជាតិប្រសិទ្ធនាមថាជា **«ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី»**។ អត្រានៃភាពក្រីក្រក៏បានថយចុះពី៤៧,៨% ក្នុងឆ្នាំ២០០៧ មកនៅក្រោម១០% ក្នុងឆ្នាំ២០១៩ ខណៈដែលផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់បានកើនដល់ប្រមាណ ១ ៧០០ ដុល្លារអាមេរិក ក្នុងឆ្នាំដដែល។

**តារាងទី១៖ សូចនាករម៉ាក្រូសេដ្ឋកិច្ច (ក្របខ័ណ្ឌខែឧសភា ឆ្នាំ២០២០ ជាធាតុចូលសម្រាប់ច្បាប់ថវិកា ឆ្នាំ២០២១)**

*ឯកតា៖ ដុល្លារអាមេរិក*

| សូចនាករម៉ាក្រូសេដ្ឋកិច្ច | ២០១៧ | ២០១៨ | ២០១៩ ប៉ាន់ស្មាន | ២០២០ ព្យាករណ៍ | ២០២១ ព្យាករណ៍ |
|---|---|---|---|---|---|
| ផសស តាមថ្លៃបច្ចុប្បន្ន (លាន) | ២២ ២០៨ | ២៤ ៦១០ | ២៧ ១៣០ | ២៧ ២២១ | ២៩ ០១៣ |
| ផសស សម្រាប់មនុស្សម្នាក់ | ១ ៤៣០ | ១ ៥៦៣ | ១ ៧០០ | ១ ៦៨៣ | ១ ៧៧១ |
| កំណើនពិតនៃ ផសស (%) | ៧,០% | ៧,៥% | ៧,១% | -១,៩% | ៣,៥% |
| អតិផរណា (ជាមធ្យមប្រចាំឆ្នាំ) | ២,៩% | ២,៥% | ១,៨% | ២,៨% | ៣,១% |
| ទុនបម្រុងជាតិ (% ផសស) | ២៣,០% | ១៨,៧% | ១៦,៩% | ១៤,៨% | ១៣,៧% |
| ទុនបម្រុងអន្តរជាតិ (% ផសស) | ៧,៩% | ១២,២% | ១៥,៥% | ១៧,៦% | ១៧,៣% |
| ទុនបម្រុងអន្តរជាតិ (លាន) | ១២ ២០១ | ១៤ ៦២៩ | ១៨ ៧៦៣ | ១៦ ៩៣៧ | ១៦ ៩៨១ |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ជាមួយសមិទ្ធផលទាំងនេះ រាជរដ្ឋាភិបាលបានកំណត់ចក្ខុវិស័យមួយច្បាស់លាស់ដើម្បីប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ប៉ុន្តែផលអវិជ្ជមាននៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ចកម្ពុជា ដែលត្រូវបានប៉ាន់ប្រមាណថា នឹងមានកំណើនអវិជ្ជមានក្នុងឆ្នាំ២០២០នេះ ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់ដំណើរការអភិវឌ្ឍជាតិ។ វិស័យដែលរងផលប៉ះពាល់ខ្លាំងជាងគេគឺ វិស័យទេសចរណ៍ ឧស្សាហកម្ម ដឹកជញ្ជូន និងអចលនទ្រព្យ។

នៅចំពោះមុខសភាពការណ៍បែបនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការបន្ទាន់ ហ្មត់ចត់ ស៊ីជម្រៅ និងមានប្រសិទ្ធភាព ដើម្បីទ្រទ្រង់ និងគាំទ្រសេដ្ឋកិច្ច-សង្គម សំដៅជួយរក្សាលំនឹងផលិតកម្ម អាជីវកម្ម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលទទួលរងគ្រោះ។ បន្ថែមពីលើនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញជាបន្តបន្ទាប់នូវវិធានការកែទម្រង់មុតស្រួចនានា ដូចជាការកែលម្អច្បាប់វិនិយោគ និងប្រព័ន្ធលើកទឹកចិត្តដើម្បីជួយសម្រួល និងបង្កបរិយាកាសល្អសម្រាប់ធុរជន និងវិនិយោគិន។

ច្បាប់វិនិយោគថ្មីនឹងផ្តល់របបវិនិយោគកាន់តែអនុគ្រោះថែមទៀត ដើម្បីទាក់ទាញធុរកិច្ចកាន់តែច្រើន ជាពិសេសបណ្តាក្រុមហ៊ុនដែលកំពុងងាកមករកទីតាំងផលិតកម្មថ្មីនៅតំបន់អាស៊ាន។ រាជរដ្ឋាភិបាលក៏កំពុងរៀបចំច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) គម្រោងធានាឥណទានរបស់រដ្ឋ ការចុះបញ្ជីតាមប្រព័ន្ធអនឡាញ (Online) គំនិតផ្តួចផ្តើមរៀបចំសេដ្ឋកិច្ចឌីជីថល។ល។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) នៅខែវិច្ឆិកា ឆ្នាំ២០២០ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងចិន នៅខែតុលា ឆ្នាំ២០២០ ព្រមទាំងដំណើរឆ្ពោះទៅមុខនៃការចរចាកិច្ចព្រមព្រៀងដូចគ្នាជាមួយសាធារណរដ្ឋកូរ៉េ គឺជាសមិទ្ធផលថ្មីរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយផលប៉ះពាល់នានាផង ជំរុញការស្តារ និងពង្រឹងសេដ្ឋកិច្ចឡើងវិញក្រោយជំងឺកូវីដ-១៩ផង។ ស្ថានការណ៍ដូចបានរៀបរាប់ខាងលើនេះ កាន់តែបញ្ជាក់ច្បាស់ពីភាពត្រឹមត្រូវ និងចាំបាច់បំផុត ក្នុងការផ្លាស់ប្តូររបៀបរបបការងារពីការធ្វើការទូតប្រពៃណី មកជាការទូតដែលផ្តោតសំខាន់ដល់ការលើកស្ទួយ និងជំរុញកំណើនសេដ្ឋកិច្ច ទេសចរណ៍ និងវប្បធម៌ ព្រមទាំងប្រែក្លាយបញ្ហាប្រឈមទាំងឡាយឱ្យក្លាយជាកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា។

នៅក្នុងស្មារតីនេះ ការអនុវត្តគោលនយោបាយ «**ការទូតសេដ្ឋកិច្ចប្រកបដោយភាពបត់បែន និងប៉ិនប្រសប់**» គឺជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពទាំង៥ នៃការដ្ឋានកំណែទម្រង់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (កបទ.សអ) ដែលទទួលបានការគាំទ្រពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** កាលពីឆ្នាំ២០១៨។ ដូចនេះ ការទូតសេដ្ឋកិច្ចបានក្លាយជាយុទ្ធសាស្ត្រអាទិភាពថ្មីមួយទៀត ដើម្បីចូលរួមពង្រឹងជន្ទល់កំណើនសេដ្ឋកិច្ច កាត់បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ និងលើកកម្ពស់ផលប្រយោជន៍កម្ពុជានៅក្នុងតំបន់ និងអន្តរជាតិ។

ការដាក់ចេញនូវយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច មានសារៈសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារការទូត។ គោលបំណងនៃយុទ្ធសាស្ត្រនេះរួមមាន៖ ការជំរុញពាណិជ្ជកម្មអន្តរជាតិ ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងការជំរុញលើកស្ទួយវិស័យទេសចរណ៍ និងវប្បធម៌របស់កម្ពុជា។ យុទ្ធសាស្ត្រនេះនឹងក្លាយជាមាគ៌ាសម្រាប់អ្នកការទូតប្រើប្រាស់ក្នុងការអនុវត្តការងារការទូតសេដ្ឋកិច្ចឱ្យចំគោលដៅ និងមានប្រសិទ្ធភាព។

## ៣. ការទូតសេដ្ឋកិច្ចកម្ពុជា

នៅចំពោះមុខការវិវឌ្ឍដ៏ឆាប់រហ័សនៃបរិយាកាសសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ដែលប្រកបទៅដោយភាពមិនប្រាកដប្រជា និងមិនស្ថិតស្ថេរ ការរក្សានូវសន្តិសុខ និងជម្រើមសេដ្ឋកិច្ចកាន់តែមានភាពចាំបាច់។ នៅក្នុងសុន្ទរកថានៃសន្និបាតប្រចាំឆ្នាំរបស់ក្រសួង កបទ.សអ កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានបញ្ជាក់ថា «**ការទូតសេដ្ឋកិច្ច**» គឺជាអាទិភាពសម្រាប់គោលនយោបាយការបរទេសកម្ពុជា ដោយមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើពិពិធកម្មប្រភពកំណើន និងដៃគូសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។ ការទូតសេដ្ឋកិច្ចនឹងជួយឱ្យកម្ពុជារក្សាបាននូវថាមភាព និងវិបុលភាពសេដ្ឋកិច្ច ក៏ដូចជាការលើកកម្ពស់កិត្យានុភាព និងតួនាទីរបស់កម្ពុជានៅលើឆាកអន្តរជាតិផងដែរ។

ក្នុងនាមជាប្រទេសដែលមានសេដ្ឋកិច្ចបើកចំហ កម្ពុជាងាយនឹងទទួលរងនូវផលប៉ះពាល់ពីការផ្លាស់ប្តូរ និងវិបត្តិពីខាងក្រៅ ជាពិសេសក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។ ដូច្នេះ កម្ពុជាចាំបាច់ត្រូវតែខិតខំទ្វេដង ដើម្បីកសាងប្រព័ន្ធសេដ្ឋកិច្ច និងសង្គមឱ្យមានភាពរឹងមាំ និងអាចឆ្លើយតបទៅនឹងវិបត្តិនេះប្រកបដោយប្រសិទ្ធភាព។ ក្នុងបរិបទនេះ ការអនុវត្តការទូតសេដ្ឋកិច្ចមានគោលដៅពង្រឹង និងលើកស្ទួយគោលនយោបាយការបរទេស ដើម្បីការពារផលប្រយោជន៍ជាតិ និងលើកកម្ពស់កិត្យានុភាពរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក ដោយផ្តោតលើវិបុលភាពសេដ្ឋកិច្ចជាប្រយោជន៍ស្នូលរបស់ជាតិ។ បេសកកម្មចម្បងនៃការទូតសេដ្ឋកិច្ចកម្ពុជា គឺបំលែងបរិយាកាស និងបញ្ហាប្រឈមអន្តរជាតិទៅជាកាលានុវត្តភាព ដែលជាប្រភពនៃកំណើន និងជាកម្លាំងសេដ្ឋកិច្ចប្រទេសជាតិ។ ការកែប្រែដោយផ្តោតលើការទូតបែបទំនើប ដែលរួមមានការទូតសេដ្ឋកិច្ច ទេសចរណ៍ វប្បធម៌ និងបច្ចេកវិទ្យាច្នៃប្រឌិត គឺជាបុរេសកម្មក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលនៃបរិបទអន្តរជាតិថ្មី។ ដើម្បីឈានទៅសម្រេចគោលដៅនេះ រាជរដ្ឋា-

ភិបាលត្រូវតែបន្តខិតខំអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ ព្រមទាំងការពង្រឹង និងពង្រីកទីផ្សារនាំចេញ ការបង្កើនការប្រកួតប្រជែងផលិតផល និងសេវាកម្ម ការទាក់ទាញវិនិយោគិន ការពង្រឹងវិស័យទេសចរណ៍ ការលើកតម្កើងតម្លៃវប្បធម៌ខ្មែរ និងការឆ្លៀតយកឱកាសទាំងឡាយណាដែលផុសចេញពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថល។

# ជំពូកទី១ - ការទូតសេដ្ឋកិច្ច

## ១. ចក្ខុវិស័យ និងបេសកកម្ម

**ការទូតសេដ្ឋកិច្ច** គឺជាការផ្សារភ្ជាប់រវាងគោលនយោបាយការបរទេស និងប្រព័ន្ធការទូតរបស់រដ្ឋ ជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពោលគឺបញ្ចូលទិដ្ឋភាពសេដ្ឋកិច្ចទៅក្នុងគោលនយោបាយការបរទេសរបស់រដ្ឋ ព្រមទាំងការប្រើប្រាស់នូវយន្តការការទូតរបស់រដ្ឋ ក្នុងគោលដៅស្វែងរកផលប្រយោជន៍សេដ្ឋកិច្ច តាមរយៈកិច្ចសហប្រតិបត្តិការជាមួយតួអង្គជាតិ និងអន្តរជាតិ និងបណ្តាប្រទេសក្នុងសកលលោក។

- **ចក្ខុវិស័យ៖** ការទូតសេដ្ឋកិច្ចនឹងពង្រឹងកិត្យានុភាពជាតិ តាមរយៈការជំរុញ និងពង្រីកផលប្រយោជន៍សេដ្ឋកិច្ចជាតិ។

- **បេសកកម្ម៖**
    1. រួមចំណែកសម្រេចនូវចក្ខុវិស័យរបស់កម្ពុជា ឱ្យក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០
    2. ពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូកាន់តែទូលំទូលាយជាមួយភាគីពាក់ព័ន្ធទាំងកម្រិតជាតិ និងអន្តរជាតិ
    3. លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាតិ។

## ២. គោលបំណងនៃយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច

គោលបំណងនៃយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចរួមមាន៖

១. ជួយជំរុញពាណិជ្ជកម្មអន្តរជាតិ

២. ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស

៣. លើកកម្ពស់វិស័យទេសចរណ៍ និង

៤. ជំរុញការផ្លាស់ប្តូរវប្បធម៌ និងកីឡា។

## ៣. គោលដៅនៃយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច

ការទូតសេដ្ឋកិច្ចមានគោលដៅបង្កើតឱ្យមានយន្តការអនុវត្តការទូតសេដ្ឋកិច្ចប្រកបដោយភាពប្រទាក់ក្រឡាគ្នា មានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីរួមចំណែករក្សាការពារនិចលភាព និងបង្កើនកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច តាមរយៈការលើកកម្ពស់ និងពង្រឹងកិច្ចសហការលើគ្រប់វិស័យ ជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

## ៤. អភិក្រម

ក្នុងក្របខ័ណ្ឌអនុវត្តការទូតសេដ្ឋកិច្ចនេះ ក្រសួង កបទ.សអ នឹងដើរតួនាទី៖ **(ទី១)** ជាអ្នកសម្របសម្រួល និងជំរុញយន្តការដែលមានស្រាប់ ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ជំរុញឱ្យមានកំណើននៃការធ្វើពាណិជ្ជកម្មទ្វេភាគី និងពហុភាគី និងទាក់ទាញភ្ញៀវទេសចរណ៍ តាមរយៈការលើកកម្ពស់តម្លៃវប្បធម៌ខ្មែរនៅក្រៅប្រទេស និង **(ទី២)** ជាអ្នកអភិវឌ្ឍធនធានអ្នកការទូតជំនាន់ថ្មីប្រកបដោយវិជ្ជាជីវៈ សមត្ថភាពខ្ពស់ សកម្មក្នុងការការពារ និងលើកស្ទួយផលប្រយោជន៍ជាតិលើគ្រប់វិស័យ។

## ៥. ក្របខ័ណ្ឌគោលនយោបាយ

### ៥.១. វិសាលភាពការងារការទូតសេដ្ឋកិច្ច

ក្របខ័ណ្ឌការងារការទូតសេដ្ឋកិច្ច ត្រូវបានរៀបចំឡើងក្រោមការពិនិត្យប្រឹក្សាលើឯកសារផ្សេងៗដូចជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម (២០១៥-២០២៥) យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (២០១៩-២០២៣) និង

ផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍ពាក់ព័ន្ធនានា។ ហេតុនេះ ការងារការទូតសេដ្ឋកិច្ចនឹងផ្តោតលើទិដ្ឋភាពអាទិភាពចំនួន៤ ដូចខាងក្រោម៖

**១. អភិវឌ្ឍធនធានមនុស្សប្រកបដោយជំនាញការទូតសេដ្ឋកិច្ច** តាមរយៈ (១) ការជ្រើសរើសមន្ត្រីប្រកបដោយគុណវុឌ្ឍិ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (២) ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល (៣) ការប្រើប្រាស់ធនធានមនុស្សដែលមានស្រាប់ (៤) ការអភិវឌ្ឍស្ថាប័ន និង(៥) ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍។

**២. លើកកម្ពស់ពាណិជ្ជកម្មអន្តរជាតិ** តាមរយៈ (១) ការជំរុញ និងធ្វើពិពិធកម្មទាំងផលិតផលនាំចេញ និងទីផ្សារនាំចេញ (២) ការស្វែងរក និងទាញយកកាលានុវត្តភាពពីទីផ្សារថ្មីៗសម្រាប់ផលិតផល និងសេវាកម្មកម្ពុជា និង(៣) ការពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូសេដ្ឋកិច្ចអន្តរជាតិ ដោយផ្តោតលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី។

**៣. ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស** តាមរយៈ (១) ការលើកកម្ពស់ការយល់ដឹងអំពីសក្តានុពល កាលានុវត្តភាព និងការលើកទឹកចិត្តលើវិស័យវិនិយោគរបស់កម្ពុជានៅលើឆាកអន្តរជាតិ (២) ការសម្របសម្រួលដំណើរទស្សនកិច្ចសម្រាប់ភាគីដែលមានសក្តានុពលមកវិនិយោគ និង(៣) ការពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន។

**៤. លើកកម្ពស់វិស័យទេសចរណ៍ វប្បធម៌ និងកីឡា** តាមរយៈ (១) ការចូលរួមលើកកម្ពស់គុណភាព និងការធ្វើពិពិធកម្មផលិតផល និងសេវាកម្ម (២) ការចូលរួមលើកកម្ពស់ការទាក់ទាញទេសចរណ៍នៃតំបន់បេតិកភណ្ឌ សម្បត្តិវប្បធម៌ និងធម្មជាតិ (៣) ការចូលរួមលើកកម្ពស់ការយល់ដឹងអំពីប្រពៃណី វប្បធម៌ជាតិ និងម្ហូបខ្មែរ និង (៤) ការចូលរួមជំរុញឱ្យមានការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការវប្បធម៌ និងកីឡា។

## ៥.២. ក្របខ័ណ្ឌសកម្មភាពការងារការទូតសេដ្ឋកិច្ច

ដើម្បីសម្រេចបាននូវផែនការខាងលើ ការទូតសេដ្ឋកិច្ចនឹងដាក់ចេញនូវយុទ្ធសាស្ត្រអន្តរាគមន៍ ដើម្បីជួយពង្រឹងការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចកម្ពុជា ដែលយុទ្ធសាស្ត្រគន្លឹះរួមមាន៖

**១. យុទ្ធសាស្ត្រផ្សព្វផ្សាយកិត្តិនាមៈ** ដើម្បីឱ្យកម្ពុជាមានកេរ្តិ៍ឈ្មោះល្អ គឺចាំបាច់ត្រូវអភិវឌ្ឍយុទ្ធសាស្ត្រទំនាក់ទំនងសាធារណៈ ដោយលើកកម្ពស់ការផ្សព្វផ្សាយដែលរំលេចអំពីឧត្តមភាពរបស់កម្ពុជា។ យុទ្ធសាស្ត្រសំខាន់ៗមានដូចជា ការផ្សព្វផ្សាយពាណិជ្ជកម្ម ការស្វែងរកទីផ្សារ ការចែករំលែកព័ត៌មាន និងការរៀបចំដំណើរកម្សាន្តទេសចរណ៍មកកម្ពុជា។ល។ សរុបសេចក្តីមក កិត្តិនាម គឺជាកត្តាចម្បងសម្រាប់ពង្រឹងការប្រកួតប្រជែងរបស់កម្ពុជា។

**២. ការប្រមូលផ្តុំព័ត៌មានសេដ្ឋកិច្ចៈ** ការប្រមូលព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច រួមមានការសិក្សាវិភាគអំពីគោលនយោបាយ និងលក្ខខណ្ឌ ដែលនឹងជួយជ្រោមជ្រែងដល់ការសម្រេចចិត្ត និងពង្រឹងឧត្តមភាពនៃការប្រកួតប្រជែងរបស់កម្ពុជាលើគូប្រកួតផ្សេងៗទៀត។ ព័ត៌មានទាំងនោះនឹងជួយរាជរដ្ឋាភិបាលក្នុងការតម្រង់ទិសដើម្បីកសាងគោលនយោបាយដែលជំរុញឱ្យកម្ពុជាអាចប្រកួតប្រជែងកាន់តែប្រសើរឡើងជាមួយប្រទេសដទៃទៀត។ លើសពីការប្រមូល និងវិភាគព័ត៌មាន ការបង្កើតទំនាក់ទំនងជិតស្និទជាមួយបុគ្គល និងស្ថាប័នពាក់ព័ន្ធនៃរដ្ឋម្ចាស់ផ្ទះ គឺមានសារៈសំខាន់ណាស់ក្នុងការបង្កើនឧត្តមភាពនៅក្នុងបរិបទនៃការប្រកួតប្រជែង។

**៣. ការផ្សារភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍ពាណិជ្ជកម្មៈ** អ្នកទទួលបានប្រយោជន៍ផ្ទាល់ពីការងារការទូតសេដ្ឋកិច្ច គឺជាសហគមន៍ពាណិជ្ជកម្ម។ ទំនាក់ទំនងរវាងរដ្ឋ និងវិស័យឯកជន គឺជាកិច្ចការចម្បងមួយក្នុងចំណោមកិច្ចការនានារបស់ស្ថាប័នពាក់ព័ន្ធនឹងការងារការទូតសេដ្ឋកិច្ច។ ការកសាងបណ្តាញអាជីព សង្គម និងការអភិវឌ្ឍភាពជាដៃគូជាកត្តាចាំបាច់ដើម្បីបណ្តុះនូវសុឆន្ទៈ និងទំនុកចិត្ត ហើយយើងអាចបង្កើតផលប្រយោជន៍រួម និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងវិស័យឯកជនឱ្យកាន់តែប្រសើរឡើង។

**៤. របៀបវារៈសេដ្ឋកិច្ចៈ** សំដៅទៅលើការលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ចដែលជាអាទិភាពមួយក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ការងារចម្បង គឺធ្វើយ៉ាងណាទាញយកផលប្រយោជន៍ពីការអនុវត្តយន្តការទ្វេភាគី និងពហុភាគីដែលមានស្រាប់ ដើម្បីជំរុញផលប្រយោជន៍សេដ្ឋកិច្ចកម្ពុជា។ យន្តការនានារបស់ក្រសួង កបទ.សអ មានដូចជា គណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី កិច្ចពិគ្រោះយោបល់នយោបាយ និងវេទិកាពហុភាគីផ្សេងៗទៀត ត្រូវបានយកមកប្រើប្រាស់ឱ្យកាន់តែល្អប្រសើរនៅក្នុងបរិបទនេះ និងរួមទាំងជួយរៀបចំទស្សនកិច្ចពាណិជ្ជកម្ម និងធុរកិច្ច និងធ្វើជាច្រកការទូតដើម្បីទាក់ទាញការផ្លាស់ប្តូរពាណិជ្ជកម្ម លើកកម្ពស់វិស័យទេសចរណ៍ និងគាំទ្រដល់វិស័យជំនាញថ្នាក់ជាតិឱ្យកាន់តែទូលំទូលាយ និងមានផ្លែផ្កា។

## ៥.៣. ស្ថាប័នទទួលខុសត្រូវ

បច្ចុប្បន្ននេះ មានក្រសួង-ស្ថាប័នមួយចំនួនកំពុងអនុវត្តសកម្មភាពសេដ្ឋកិច្ច ដើម្បីលើកកម្ពស់ផលប្រយោជន៍ជាតិ ទៅតាមកម្រិត និងរូបភាពផ្សេងៗគ្នា។ ក្រសួង កបទ.សអ តាមរយៈស្ថានតំណាងនៅក្រៅប្រទេស បានចូលរួមចំណែកក្នុងការងារការទូតសេដ្ឋកិច្ចយូរណាស់មកហើយ ទោះបីជាមានសកម្មភាពខ្លះមិនទាន់មានសង្គតិភាពនឹងគ្នានៅឡើយ។ ដើម្បីសម្រេចគោលបំណងខាងលើ ក្រសួង កបទ.សអ បានបង្កើតអង្គភាពមួយដើម្បីសម្របសម្រួល និងដឹកនាំរៀបចំសកម្មភាពការទូតសេដ្ឋកិច្ចនេះ។

ក្នុងការអនុវត្តការងារការទូតសេដ្ឋកិច្ច ស្ថានតំណាងកម្ពុជានៅក្រៅប្រទេស ដែលរួមមាន អ្នកការទូត និងអនុព័ន្ធជំនាញនឹងត្រូវដើរតួនាទីជួរមុខក្នុងការលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ចជាតិនៅក្រៅប្រទេស។ ដោយឡែក ក្រសួង កបទ.សអ ជាពិសេសក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ចនឹងខិតខំបង្កើនការសម្របសម្រួលរវាងស្ថាប័នរដ្ឋ ស្ថាប័នឯកជន និងស្ថានតំណាងកម្ពុជានៅក្រៅប្រទេស។

## ៥.៤. បញ្ហាប្រឈម

ដើម្បីធានាឱ្យការអនុវត្តការទូតសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងទទួលបានជោគជ័យ បញ្ហាប្រឈមធំៗមួយចំនួនដែលត្រូវតែយកចិត្តទុកដាក់ដោះស្រាយរួមមាន៖

- ក្របខ័ណ្ឌស្ថាប័នសម្រាប់ការកំណត់គោលនយោបាយ ទិសដៅ និងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច
- ធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ
- ធនធានហិរញ្ញវត្ថុគាំទ្រដល់ការអនុវត្តផែនការសកម្មភាពនានា
- យន្តការសម្របសម្រួលអន្តរវិស័យ និងយន្តការចែករំលែកព័ត៌មាន ក្នុងចំណោមតួអង្គពាក់ព័ន្ធ
- យុទ្ធនាការផ្សព្វផ្សាយកិត្តិនាម និងទីផ្សារ រួមទាំងការធ្វើសកម្មភាពបញ្ចុះបញ្ចូល (បណ្តាញប្រាស័យទាក់ទង)។

# ជំពូកទី២ - យុទ្ធសាស្ត្រ

ដើម្បីសម្រេចឱ្យបានជោគជ័យស្របតាមគោលដៅខាងលើ ក្រសួង កបទ.សអ បាន ដាក់ចេញនូវយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ ដូចខាងក្រោម៖

## ១. ការកសាងធនធានមនុស្ស

ធនធានមនុស្ស គឺជាធាតុសំខាន់បំផុតក្នុងការអភិវឌ្ឍប្រទេសជាតិ ដូចមានចង្អុលបង្ហាញនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (២០១៨-២០២៣) ដែលផ្តោតសំខាន់លើការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការបណ្តុះបណ្តាលបច្ចេកទេស។ ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យការទូត និងកិច្ចការការបរទេស ត្រូវបានមើលឃើញថា មានការវិវឌ្ឍជាជំហានៗ បន្ទាប់ពីវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៦។ ទោះបីជាយ៉ាងនេះក្តី យើងនៅមានតម្រូវការកម្មវិធីអភិវឌ្ឍន៍សមត្ថភាពបន្ថែមទៀត ដើម្បីបំពាក់បំប៉នមន្ត្រីការទូតជាមួយនឹងចំណេះដឹង និងជំនាញថ្មីៗ ជាពិសេសពាក់ព័ន្ធនឹងវិស័យការទូតសេដ្ឋកិច្ច។

ហេតុដូច្នេះ ការបង្កើតកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពលើផ្នែកការទូតសេដ្ឋកិច្ចសម្រាប់អ្នកការទូត និងអ្នកពាក់ព័ន្ធដទៃទៀតឱ្យបានគ្រប់ជ្រុងជ្រោយ ពិតជាមានសារៈសំខាន់ដល់ការលើកស្ទួយផលប្រយោជន៍សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ទាំងក្នុង និងក្រៅប្រទេស។ ប្រធានបទសំខាន់ៗដែលត្រូវយកមកបំពាក់បំប៉ននៅក្នុងកម្មវិធីបណ្តុះបណ្តាលផ្នែកការទូតសេដ្ឋកិច្ចមានដូចជា ជំនាញប្រាស្រ័យទាក់ទង ការផ្សព្វផ្សាយពីកិត្តិនាមជាតិ ការចរចាពាណិជ្ជកម្ម និងការសម្របសម្រួលពាណិជ្ជកម្ម ការជំរុញការវិនិយោគ ការលើកកម្ពស់ការផ្សព្វផ្សាយទេសចរណ៍ និងយុទ្ធសាស្ត្រទីផ្សារសម្រាប់ផលិតផល និងសេវាកម្មរបស់កម្ពុជា រួមទាំងការយល់ដឹងពីទិដ្ឋភាពច្បាប់ វិនិយោគ និងសេដ្ឋកិច្ចកម្ពុជា និងអន្តរជាតិ។

## ២. ការលើកកម្ពស់យន្តការទំនាក់ទំនង និងចែករំលែកព័ត៌មាន

ការកសាងបណ្តាញទំនាក់ទំនង និងយន្តការចែករំលែកព័ត៌មានរវាងក្រសួង-ស្ថាប័នរដ្ឋ និងភាគីពាក់ព័ន្ធពិតជាមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពសម្រាប់វិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងការផ្លាស់

ប្តូរវប្បធម៌។ ក្នុងន័យនេះ ព័ត៌មាន និងគម្រោងសកម្មភាពនានានឹងត្រូវចែករំលែកជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីស្រង់មតិយោបល់ពីក្រសួង-ស្ថាប័នទាំងនេះក្នុងការរួមដៃគ្នាស្វែងរក និងកំណត់ផលប្រយោជន៍សេដ្ឋកិច្ចរបស់កម្ពុជា ហើយតម្រង់ទិសដៅការងារប្រកបដោយប្រសិទ្ធភាព។

បន្ថែមលើនេះ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីកិត្តិសព្ទល្បីរន្ទឺនៃប្រាសាទអង្គរវត្ត ដែលជានិមិត្តរូបនៃ «**ព្រះរាជាណាចក្រអច្ឆរិយៈ**» គឺជាកម្លាំងចលករដ៏សំខាន់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ក្នុងការបង្កើនប្រាក់ចំណូល តាមរយៈការទាក់ទាញភ្ញៀវទេសចររាប់លាននាក់ចូលមកទស្សនាប្រទេសកម្ពុជា បង្កើតការងារ បង្កើនមូលធន និងបង្កើនខ្សែចង្វាក់ផលិតកម្ម។ អ្នកការទូតកម្ពុជាដែលទទួលបានការបណ្តុះបណ្តាលពេញលេញ និងមានចំណេះដឹងទូលំទូលាយផ្នែកការទូតវប្បធម៌ អាចជួយផ្សព្វផ្សាយកិត្តិនាម និងលើកតម្កើនកិត្យានុភាពរបស់ប្រទេសកម្ពុជានៅលើឆាកអន្តរជាតិ។ ម្យ៉ាងវិញទៀត ពួកគាត់មិនត្រូវមើលរំលងឡើយនូវវប្បធម៌អរូបីយ ដែលចាំបាច់ត្រូវដាក់បញ្ចូលក្នុងយុទ្ធសាស្ត្ររួមនៃការទូតសេដ្ឋកិច្ច ដូចជា តន្ត្រី ល្ខោន ម្ហូបអាហារ។ល។

## ៣. ការលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន

ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក៏ដូចជាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ។ ហេតុនេះ ចាំបាច់ត្រូវបង្កើនទំនាក់ទំនងជិតស្និទរវាងរដ្ឋ និងវិស័យឯកជន តាមរយៈការបង្កើតបណ្តាញទំនាក់ទំនង ការកសាងភាពជាដៃគូរវាងស្ថាប័នសាធារណៈ និងសហគមន៍ពាណិជ្ជកម្ម ដើម្បីកំណត់នូវកាលានុវត្តភាព រៀបចំគោលនយោបាយ និងស្វែងរកចន្លោះប្រហោងនៃការអនុវត្ត និងបង្កើតចក្ខុវិស័យរួមគ្នាឆ្ពោះទៅរកការសម្រេចបាននូវផលប្រយោជន៍ជាតិ។

# ជំពូកទី៣ - ផែនការសកម្មភាពរួមតាមដំណាក់កាល

## ១. ដំណាក់កាលទី១៖ ឆ្នាំ២០២១

- ពង្រឹងសមត្ថភាពអ្នកការទូត និងភាគីពាក់ព័ន្ធនានា ដើម្បីអនុវត្តការទូតសេដ្ឋកិច្ច
- បង្កើតលក្ខខណ្ឌការងារសម្រាប់អ្នកការទូតសេដ្ឋកិច្ច
- ប្រមូល ចងក្រង និងចែករំលែកជាទៀងទាត់នូវព័ត៌មានពាក់ព័ន្ធនឹងសេដ្ឋកិច្ច-សង្គមជាមួយស្ថាប័នពាក់ព័ន្ធ
- ពង្រឹងកិច្ចសហការ និងសម្របសម្រួលរវាងរដ្ឋ និងវិស័យឯកជន
- ចាប់ផ្ដើមអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសអនុវត្ត។

## ២. ដំណាក់កាលទី២៖ ឆ្នាំ២០២២

- បង្កើតកម្មវិធីចែកចាយព័ត៌មាន ដើម្បីរក្សាទុក និងចែកចាយបន្ត
- បន្តការបណ្ដុះបណ្ដាលស្ដីពីការទូតសេដ្ឋកិច្ចដល់អ្នកការទូតកម្ពុជា និងភាគីពាក់ព័ន្ធ
- ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងកិច្ចសន្ទនាពហុភាគី ដើម្បីផលប្រយោជន៍សេដ្ឋកិច្ចកម្ពុជា
- លើកកម្ពស់ការអនុវត្តការងារការទូតសេដ្ឋកិច្ចកម្ពុជា
- បន្តតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសអនុវត្ត។

## ៣. ដំណាក់កាលទី៣៖ ឆ្នាំ២០២៣

- បន្តការបណ្ដុះបណ្ដាលស្ដីពីការទូតសេដ្ឋកិច្ចដល់អ្នកការទូតកម្ពុជា និងភាគីពាក់ព័ន្ធ
- បន្តអភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់នូវយន្តការដើម្បីគាំទ្រដល់កម្មវិធីចែកចាយព័ត៌មានសម្រាប់ការអនុវត្តការទូតសេដ្ឋកិច្ច
- បន្តលើកកម្ពស់ការអនុវត្តការងារការទូតសេដ្ឋកិច្ច
- សរុប និងវាយតម្លៃសមិទ្ធកម្មយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣
- រៀបចំយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២៤-២០២៨។

❖ *ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ មានភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃឯកសារនេះ។*

# ជំពូកទី៤ - ធនធានហិរញ្ញវត្ថុ

## ១. តម្រូវការថវិកា

ដើម្បីជានាការអនុវត្តផែនការយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ ឱ្យសម្រេចបានជោគជ័យ ក្រសួង កបទ.សអ ត្រូវការថវិកាសរុបចំនួនប្រមាណ ១៣ ៧០០ លានរៀល ក្នុងនោះថវិកាចរន្តត្រូវការចំនួនប្រមាណ ១១ ៧០០ លានរៀល និងថវិកាវិនិយោគត្រូវការចំនួន ២ ០០០ លានរៀល ដូចមានលម្អិតក្នុងឧបសម្ព័ន្ធទី១ នៃឯកសារនេះ។

## ២. ប្រភពថវិកា

ថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ មានប្រភពមកពី៖

- ថវិកាជាតិ
- ជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា
- វិភាគទានពីវិស័យឯកជន និង
- ប្រភពស្របច្បាប់នានា។

# ជំពូកទី៥ - ការតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃ គឺជាតម្រូវការចាំបាច់ដើម្បីធានាដល់ការអនុវត្តសកម្មភាព និងសូចនាករនានាដែលបានកំណត់ផែនការយុទ្ធសាស្ត្រនេះ។ ដូច្នេះ សូចនាករគោលដៅ គឺជាឧបករណ៍ដ៏ស័ក្តិសិទ្ធិសម្រាប់ផ្ទៀងផ្ទាត់ តាមដានត្រួតពិនិត្យ និងវាយតម្លៃសូចនាករលទ្ធផលនៅពាក់កណ្តាលអាណត្តិ និងពេញអាណត្តិនៃការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣។ ក្នុងន័យនេះ គ្រប់អង្គភាពពាក់ព័ន្ធត្រូវរៀបចំផែនការសកម្មភាពលម្អិត និងកំណត់សូចនាករលទ្ធផលឱ្យបានច្បាស់លាស់សម្រាប់តាមដាន អនុវត្ត និងធ្វើបច្ចុប្បន្នភាព ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងនវានុវត្តន៍នៃសេដ្ឋកិច្ច និងសង្គមកម្ពុជា។

របាយការណ៍ការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ ត្រូវមានទម្រង់ស្តង់ដារមួយ ដែលមានធាតុចូលសំខាន់សម្រាប់ជាមូលដ្ឋានតាមដានត្រួតពិនិត្យ

វាយតម្លៃ និងបទពិសោធន៍នៃការអនុវត្តយុទ្ធសាស្ត្រនេះ។ ទម្រង់នៃរបាយការណ៍នេះនឹងត្រូវប្រើប្រាស់ដោយស្ថានតំណាងកម្ពុជានៅបរទេស និងអង្គភាពពាក់ព័ន្ធ ដើម្បីធ្វើរបាយ-ការណ៍លទ្ធផលប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំជូនក្រសួង (ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច)។

ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាពនៃការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ ក្នុងរយៈពេលមធ្យមនេះ ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ចមានតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យមានភាពប្រទាក់ក្រឡាគ្នារវាងការអនុវត្តផែនការសកម្មភាពការទូតសេដ្ឋកិច្ច និងការអនុវត្តថវិកា និងសម្រេចបានគោលដៅសមិទ្ធកម្មចុងក្រោយ។ ក្នុងន័យនេះ ផ្អែកលើមូលដ្ឋាននៃរបាយការណ៍លទ្ធផលការងាររបស់អង្គភាពពាក់ព័ន្ធ ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ចត្រូវធ្វើការវិភាគ ពិគ្រោះយោបល់ឱ្យបានគ្រប់ជ្រុងជ្រោយ និងល្អិតល្អន់ជាមួយភាគីពាក់ព័ន្ធនានា រួចចេញជារបាយការណ៍វាយតម្លៃលទ្ធផល និងស្នើនូវវិធានការនានាគោរពជូនរដ្ឋមន្ត្រីពិនិត្យ និងសម្រេច។

របាយការណ៍វាយតម្លៃនេះ គឺមានសារៈសំខាន់សម្រាប់តួអង្គពាក់ព័ន្ធដែលអនុវត្តយុទ្ធសាស្ត្រនេះ និងជាពិសេសសម្រាប់ថ្នាក់ដឹកនាំរបស់ក្រសួង កបទ.សអ ក្នុងការសម្រេចចិត្ត និងទទួលខុសត្រូវលើការប្រើប្រាស់ធនធានជាតិ។

# សេចក្តីសន្និដ្ឋាន

យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣គឺជាឧបករណ៍គោលនយោបាយមួយដើម្បីចូលរួមចំណែកលើកស្ទួយវិស័យពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ជំរុញលើកស្ទួយវិស័យទេសចរណ៍ និងវប្បធម៌ជាតិ លើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា និងគាំទ្រដល់ការធ្វើកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដែលបានកំណត់នៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភាជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ យុទ្ធសាស្ត្រនេះនឹងផ្សារភ្ជាប់គោលនយោបាយការបរទេស និងប្រព័ន្ធការទូតរបស់រដ្ឋជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពោលគឺបញ្ចូលទិដ្ឋភាពសេដ្ឋកិច្ចទៅក្នុងគោលនយោបាយការបរទេស ដោយប្រើប្រាស់នូវយន្តការការទូតរបស់រដ្ឋក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងពិភពលោក តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការ

ទ្វេភាគី និងពហុភាគីឱ្យកាន់តែស៊ីជម្រៅ និងទូលំទូលាយ ដើម្បីធ្វើពិពិធកម្មប្រភពកំណើនសេដ្ឋកិច្ច និងការប្រែក្លាយបញ្ហាប្រឈមនានាទៅជាកាលានុវត្តភាពនៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចនឹងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធានាឱ្យបាននូវការបង្កើតការងារប្រកបដោយសមធម៌ និងប្រសិទ្ធភាពឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងបន្តរួមចំណែកដើម្បីសម្រេចបាននូវចក្ខុវិស័យរយៈពេលមធ្យម និងរយៈពេលវែងរបស់កម្ពុជាជាពិសេសគោលនយោបាយស្តារ និងអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ក្នុងអំឡុងពេល និងក្រោយដំណាក់កាលរីករាលដាលនៃជំងឺកូវីដ-១៩។

ជាការពិតណាស់ ការអនុវត្តបានជោគជ័យនូវយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចនឹងរួមចំណែកពង្រឹងជន្ទល់កំណើនសេដ្ឋកិច្ច កាត់បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ លើកកម្ពស់ផលប្រយោជន៍កម្ពុជានៅក្នុងតំបន់ និងអន្តរជាតិ ជាពិសេសបំពេញបាននូវសេចក្តីត្រូវការរបស់ប្រជាជនកម្ពុជាទាំងក្នុង និងក្រៅប្រទេស។

ដើម្បីឈានទៅសម្រេចគោលដៅនេះ ក្រសួង កបទ.សអ នឹងបន្តខិតខំអភិវឌ្ឍធនធានអ្នកការទូតប្រកបដោយគុណវុឌ្ឍិ និងពង្រឹងសមត្ថភាពស្ថាប័នដើម្បីគាំទ្រសកម្មភាពការទូតសេដ្ឋកិច្ច។ ការងារនេះក៏ទាមទារឱ្យមានឆន្ទៈនយោបាយ ការប្តេជ្ញាចិត្តខ្ពស់ ការចូលរួមយ៉ាងក្លៀវក្លា និងការខិតខំប្រឹងប្រែងពីសំណាក់តួអង្គពាក់ព័ន្ធទាំងអស់ ទាំងរដ្ឋ និងវិស័យឯកជន ដើម្បីសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ និងស្វែងរកដំណោះស្រាយប្រកបដោយនវានុវត្តន៍។ ស្របពេលជាមួយគ្នានេះ មន្ត្រីរាជការស៊ីវិលចាំបាច់ត្រូវផ្លាស់ប្តូរនូវផ្នត់គំនិត និងអាកប្បកិរិយាក្នុងការបំពេញកាតព្វកិច្ចបម្រើប្រទេសជាតិ ដោយប្រកាន់ខ្ជាប់នូវអភិក្រមទាំង៥យ៉ាងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ៖ **«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»** និងបាវចនា **«កែទម្រង់ខាងក្នុង កសាងមិត្តខាងក្រៅ ដោយឈរលើមូលដ្ឋានឯករាជ្យ»**។

# ឧបសម្ព័ន្ធទី១៖
## ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច
## ឆ្នាំ២០២១-២០២៣

| ដំណាក់កាលទី១ | គម្រោងថវិកាចំនួន ៣ ១០០លានរៀល |
|---|---|
| គោលដៅរួមសម្រាប់ដំណាក់កាលទី១៖ កសាងមូលដ្ឋានគ្រឹះរបស់ស្ថាប័នដើម្បីអនុវត្ត និងវាយតម្លៃយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២១-២០២៣ | |
| លទ្ធផលរំពឹងទុក៖<br>១. សមត្ថភាពអ្នកការទូត និងភាគីពាក់ព័ន្ធនានាដើម្បីអនុវត្តការទូតសេដ្ឋកិច្ចត្រូវបានពង្រឹង<br>២. លក្ខខណ្ឌការងារសម្រាប់អ្នកការទូតសេដ្ឋកិច្ចត្រូវបានបង្កើត<br>៣. ព័ត៌មានពាក់ព័ន្ធនឹងសេដ្ឋកិច្ច-សង្គមត្រូវបានប្រមូល ចងក្រង និងចែករំលែកជាទៀងទាត់ជាមួយស្ថាប័នពាក់ព័ន្ធ<br>៤. កិច្ចសហការ និងសម្របសម្រួលរវាងរដ្ឋ និងវិស័យឯកជនត្រូវបានពង្រឹង<br>៥. យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ ត្រូវបានចាប់ផ្តើមអនុវត្ត<br>៦. តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសអនុវត្ត | |
| រយៈពេលរំពឹងទុក៖ ខែមករា - ធ្នូ ឆ្នាំ២០២១ | |

| សកម្មភាព | សូចនាករគន្លឹះ | លទ្ធផលរំពឹងទុក | តួនាទី និងទំនួលខុសត្រូវ | រយៈពេល (ត្រីមាស) | | | | គម្រោងថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|
| | | | | ទី១ | ទី២ | ទី៣ | ទី៤ | |
| ១.១. ពង្រឹងសមត្ថភាពអ្នកការទូត និងភាគីពាក់ព័ន្ធនានាដើម្បីអនុវត្តការទូតសេដ្ឋកិច្ច<br>លទ្ធផលគន្លឹះ៖<br>• បានរៀបចំរបាយការណ៍វាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស<br>• បានបង្កើតកម្មវិធីបណ្តុះបណ្តាល<br>• បានវាយតម្លៃសមត្ថភាព និងបណ្តុះបណ្តាលជំនាញការទូតសេដ្ឋកិច្ចដល់អ្នកការទូត និងភាគីពាក់ព័ន្ធ | | | | | | | | ៨០០ |
| ១.១.១. ធ្វើការវាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស | • របាយការណ៍វាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស | • ការវាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្សត្រូវបានរៀបចំជារបាយការណ៍ | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>• នាយកដ្ឋានបុគ្គលិក<br>• នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី១ | | | | ៥០ |
| ១.១.២. កំណត់ និងជ្រើសរើសសិក្ខាកាមដែលមានសក្តានុពលដើម្បីចូលរួមវគ្គបណ្តុះបណ្តាល | • ការជ្រើសរើសសិក្ខាកាមប្រកបដោយយុទ្ធសាស្ត្រ<br>• ចំនួនក្រុមនៃសិក្ខាកាម<br>• ចំនួនសិក្ខាកាមចូលរួមក្នុងមួយវគ្គបណ្តុះបណ្តាល | • ឯកសារស្តីពីលក្ខខណ្ឌក្នុងការជ្រើសរើសសិក្ខាកាមត្រូវបានរៀបចំ<br>• បានកំណត់ចំនួនក្រុមនៃសិក្ខាកាម<br>• បានកំណត់ចំនួនសិក្ខាកាមក្នុងមួយវគ្គបណ្តុះបណ្តាល | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>• នាយកដ្ឋានបុគ្គលិក | ត្រីមាសទី១ | | | | ៥០ |

| | | | | | |
|---|---|---|---|---|---|
| ១.១.៣. បង្កើត និងបែងចែកវគ្គបណ្តុះបណ្តាល និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលស្តីពីការទូតសេដ្ឋកិច្ចសម្រាប់៖<br>ក. អ្នកការទូត<br>ខ. កុងស៊ុល<br>គ. មន្ត្រី<br>ឃ. មន្ត្រីក្របខ័ណ្ឌថ្មី<br>ង. ភាគីពាក់ព័ន្ធ | •រយៈពេលនៃវគ្គបណ្តុះបណ្តាល<br>•ប្រភេទ និងចំនួនកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកការទូត និងភាគីពាក់ព័ន្ធ | •កម្មវិធីបណ្តុះបណ្តាលត្រូវបានបង្កើតជាចំដោយឡែកពីគ្នាសម្រាប់អ្នកការទូត (ឯកអគ្គរាជទូត កុងស៊ុល និងកុងស៊ុលកិត្តិយស) និងភាគីពាក់ព័ន្ធ | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>•នាយកដ្ឋានបុគ្គលិក | ត្រីមាសទី១-២ | ១០០ |
| ១.១.៤. រៀបចំសិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកការទូត និងភាគីពាក់ព័ន្ធ | •ចំនួនសិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាល<br>•ចំនួនសិក្ខាកាមចូលរួមក្នុងមួយសិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាល | •អ្នកការទូត និងភាគីពាក់ព័ន្ធបានចូលរួមសិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាល ដើម្បីពង្រឹងជំនាញការទូតសេដ្ឋកិច្ច<br>•អ្នកការទូតត្រូវបានបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈ | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>•នាយកដ្ឋានបុគ្គលិក | ត្រីមាសទី២-៤ | ៣០០ |
| ១.១.៥. ការបណ្តុះបណ្តាលគ្រូបង្គោល | •រយៈពេលនៃវគ្គបណ្តុះបណ្តាល<br>•ចំនួនគ្រូបង្គោល<br>•ការអភិវឌ្ឍសម្ភារៈគរុកោសល្យ និងបណ្តុះបណ្តាល | •គ្រូបង្គោលមានសមត្ថភាពក្នុងការចែករំលែកបទពិសោធន៍ចំណេះដឹង និងចំណេះធ្វើស្តីពីការទូតសេដ្ឋកិច្ច<br>•សម្ភារៈគរុកោសល្យ និងបណ្តុះបណ្តាល ត្រូវបានបង្កើតសម្រាប់វគ្គបណ្តុះបណ្តាលនីមួយៗ | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>•នាយកដ្ឋានបុគ្គលិក<br>•នាយកដ្ឋានពាក់ព័ន្ធ<br>•ក្រសួង និងស្ថាប័នពាក់ព័ន្ធ | ត្រីមាសទី៣ | ៣០០ |

| | | | | | |
|---|---|---|---|---|---|
| ១.២. បង្កើតលក្ខខណ្ឌការងារសម្រាប់អ្នកការទូតសេដ្ឋកិច្ច<br>លទ្ធផលគន្លឹះ៖<br>• បានបង្កើត និងអនុវត្តលក្ខខណ្ឌការងារសម្រាប់អ្នកការទូតសេដ្ឋកិច្ច | | | | | ៥០ |
| ១.២.១. បង្កើត និងអនុវត្តលក្ខខណ្ឌការងារសម្រាប់អ្នកការទូតសេដ្ឋកិច្ច(ជាពិសេសអ្នកការទូតដែលត្រៀមចេញទៅបំពេញបេសកកម្មក្រៅប្រទេស) | • លក្ខខណ្ឌការងារសម្រាប់អ្នកការទូតសេដ្ឋកិច្ច | • លក្ខខណ្ឌការងារ និងភារកិច្ចរបស់អ្នកការទូតសេដ្ឋកិច្ចត្រូវបានបង្កើត | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• នាយកដ្ឋានបុគ្គលិក<br>• វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>• នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី១ | ៥០ |
| ១.៣. ប្រមូល ចងក្រង និងចែករំលែកជាទៀងទាត់នូវព័ត៌មានពាក់ព័ន្ធនឹងសេដ្ឋកិច្ច-សង្គម ជាមួយស្ថាប័នពាក់ព័ន្ធ<br>លទ្ធផលគន្លឹះ៖<br>• បានប្រមូល ចងក្រង និងចែករំលែកព័ត៌មានសេដ្ឋកិច្ច-សង្គម ព័ត៌មានទំនាក់ទំនង និងទិន្នន័យការទូតសេដ្ឋកិច្ចតាមរយៈផ្ទាំងផ្តល់ព័ត៌មាន | | | | | ៣០០ |
| ១.៣.១. ប្រមូល ចងក្រង និងចែករំលែកព័ត៌មានទំនាក់ទំនងនៃភាគីជាតិ និងអន្តរជាតិ ព័ត៌មានសេដ្ឋកិច្ច-សង្គម និងទិន្នន័យអំពីសកម្មភាព និងផែនការការទូតសេដ្ឋកិច្ច | • ផ្ទាំងផ្តល់ព័ត៌មានត្រូវបានធ្វើបច្ចុប្បន្នភាព<br>• ចំនួនភាគីទំនាក់ទំនង និងបុគ្គលទំនាក់ទំនងគន្លឹះ ទៅតាមវិស័យ ក្រុម និងផ្ទាំនីមួយៗ | • ព័ត៌មានសេដ្ឋកិច្ច-សង្គម ព័ត៌មានទំនាក់ទំនង និងទិន្នន័យអំពីសកម្មភាព និងផែនការការទូតសេដ្ឋកិច្ច ដែលបានមកពីរដ្ឋ និងវិស័យឯកជនត្រូវបានប្រមូល ចងក្រង និងចែករំលែកតាមរយៈផ្ទាំងផ្តល់ព័ត៌មាន<br>• បណ្តាញទំនាក់ទំនងត្រូវបានតម្កល់ទុក និងរក្សាសម្រាប់ពេលអនាគត | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• នាយកដ្ឋានព័ត៌មានវិទ្យា<br>• ស្ថានបេសកកម្មកម្ពុជានៅបរទេស | ត្រីមាសទី១-៤ | ៣០០ |

| ១.៤. ពង្រឹងកិច្ចសហការ និងសម្របសម្រួលរវាងរដ្ឋ និងវិស័យឯកជន<br>លទ្ធផលគន្លឹះ៖<br>• បានសហការ និងសម្របសម្រួលយ៉ាងសកម្មជាមួយដៃគូជាតិ និងអន្តរជាតិ ដើម្បីលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ចជាតិ | | | | | ៣៥០ |
|---|---|---|---|---|---|
| ១.៤.១. រៀបចំប្រតិទិននៃសកម្មភាព និងព្រឹត្តិការណ៍នានាដើម្បីផ្តល់ឱកាសឱ្យបុគ្គលគន្លឹះទាំងឡាយបានជួបជុំគ្នាដើម្បីលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ និងវប្បធម៌ | •ចំនួនការចូលមើលគេហទំព័រ ផ្ទាំងផ្តល់ព័ត៌មាន ឬកម្មវិធីផ្សព្វផ្សាយ<br>•ចំនួនបុគ្គលគន្លឹះដែលបានទាក់ទងមកសុំការគាំទ្រ ឬការសហការ<br>•ចំនួនព្រឹត្តិការណ៍ដែលបានរៀបចំក្នុងមួយឆ្នាំ | •ប្រតិទិននៃកម្រងសកម្មភាព និងព្រឹត្តិការណ៍ត្រូវបានបង្កើត<br>•បានផ្តល់ឱកាសឱ្យបុគ្គលគន្លឹះទាំងឡាយជួបជុំគ្នា | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>•នាយកដ្ឋានព័ត៌មានវិទ្យា<br>•ក្រសួង និងស្ថាប័នពាក់ព័ន្ធ<br>•ដៃគូពាណិជ្ជកម្ម | ត្រីមាសទី១-៤ | ៥០ |
| ១.៤.២. សហការ និងសម្របសម្រួលជាមួយដៃគូជាតិ និងអន្តរជាតិតាមរយៈព្រឹត្តិការណ៍ និងសកម្មភាពនានា ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងកម្ពុជា និងប្រទេសដទៃ | •ចំនួនព្រឹត្តិការណ៍ដែលបានសហការរៀបចំ<br>•គោលការណ៍ណែនាំអំពីកិច្ចសហប្រតិបត្តិការ និងការអនុវត្ត<br>•របៀបវារៈនៃកិច្ចប្រជុំដែលគ្រោងនឹងរៀបចំ<br>•ចំណុចពិភាក្សា និងការធ្វើបទបង្ហាញ | •តំណាងស្ថានបេសកកម្ម សភាពាណិជ្ជកម្មបរទេស និងសមាគមជនបរទេសទាំងក្នុង និងក្រៅប្រទេស រួមទាំងវិស័យឯកជនបានចូលរួមសហការយ៉ាងសកម្ម<br>•កិច្ចប្រជុំ និងវេទិកាពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ និងវិស័យឯកជនត្រូវបានរៀបចំធ្វើឡើងជាទៀងទាត់<br>•ធាតុចូល និងមតិត្រលប់របស់រដ្ឋ និងវិស័យឯកជនត្រូវបានចែករំលែក<br>•គោលការណ៍ណែនាំរួមដែលនឹងធានាដល់ភាពរលូននៃកិច្ចសហប្រតិបត្តិការ និងការអនុវត្តការទូតសេដ្ឋកិច្ចត្រូវបានបង្កើត | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•អ្នកតំណាងរដ្ឋ និងវិស័យឯកជន និងអ្នកពាក់ព័ន្ធ<br>•ស្ថានបេសកកម្មកម្ពុជានៅបរទេស | ត្រីមាសទី៣-៤ | ៣០០ |

| | | | | | |
|---|---|---|---|---|---|
| ១.៥. ចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣<br>លទ្ធផលគន្លឹះ៖<br>• បានសហការជាមួយភាគីពាក់ព័ន្ធដើម្បីលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ចជាតិ<br>• បានរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស និងទេសចរណ៍ | | | | | ១ ៥០០ |
| ១.៥.១. កំណត់ឱ្យបាននូវដៃគូគន្លឹះ និងកាលានុវត្តភាពសេដ្ឋកិច្ច | • ចំនួនដៃគូគន្លឹះ និងកាលានុវត្តភាពសេដ្ឋកិច្ចតាមវិស័យ គម្រោង និងទំហំ | • ដៃគូគន្លឹះ និងកាលានុវត្តភាពសេដ្ឋកិច្ចត្រូវបានកំណត់<br>• បានរួមចំណែកយ៉ាងសកម្មដល់កំណើនសេដ្ឋកិច្ច តាមរយៈការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស និងទេសចរណ៍ | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>• នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី៣-៤ | ៧៥០ |
| ១.៥.២. បន្តសហការជាមួយដៃគូ និងស្ថាប័នគន្លឹះ | • កិច្ចសហការជាមួយដៃគូ និងស្ថាប័នគន្លឹះប្រកបដោយចីរភាព និងអត្ថប្រយោជន៍ | • ភាគីទំនាក់ទំនងរបស់ស្ថានបេសកកម្មនៅបរទេស និងក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ចបានសហការយ៉ាងសកម្មជាមួយដៃគូ ឬភាគីពាក់ព័ន្ធគន្លឹះ<br>• កិច្ចសហការបានបង្កើតអត្ថប្រយោជន៍រួម និងប្រកបដោយចីរភាព | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>• នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី៣-៤ | ៧៥០ |

| | | | | | |
|---|---|---|---|---|---|
| ១.៦. ធ្វើការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសអនុវត្ត<br>លទ្ធផលគន្លឹះ៖<br>• បានបង្កើតវិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារ<br>• បានពង្រឹងការអនុវត្តការងារការទូតសេដ្ឋកិច្ចតាមរយៈការយល់ដឹងកាន់តែច្បាស់ និងចូលរួមកាន់តែសកម្មក្នុងសកម្មភាពលើកកម្ពស់សេដ្ឋកិច្ច | | | | | ១០០ |
| ១.៦.១. បង្កើតវិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | • របាយការណ៍វាយតម្លៃការអនុវត្តការងារ | • ទម្រង់របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានបង្កើត | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី១-២ | ៥០ |
| ១.៦.២. របាយការណ៍វាយតម្លៃការអនុវត្តការងារ | • ការវិភាគ ការស្រាវជ្រាវ ដំណោះស្រាយ ឬអនុសាសន៍ | • ការអនុវត្តការងារការទូតសេដ្ឋកិច្ចត្រូវបានលើកកម្ពស់<br>• បញ្ហាប្រឈមចម្បងៗត្រូវបានដោះស្រាយ<br>• ផែនការសកម្មភាពសម្រាប់ដំណាក់កាលបន្ទាប់ត្រូវបានរៀបចំកាន់តែល្អប្រសើរ | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី៤ | ៥០ |

## ដំណាក់កាលទី២ — គម្រោងថវិកាចំនួន ៥ ៥០០លានរៀល

**គោលដៅរួមសម្រាប់ដំណាក់កាលទី២៖ លើកកម្ពស់ការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច**

**លទ្ធផលរំពឹងទុក៖**

១. កម្មវិធីចែកចាយព័ត៌មានត្រូវបានបង្កើត

២. ការបណ្តុះបណ្តាលស្តីពីការទូតសេដ្ឋកិច្ចដល់អ្នកការទូតកម្ពុជា និងភាគីពាក់ព័ន្ធត្រូវបានបន្តអនុវត្ត

៣. ភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកិច្ចសន្ទនាពហុភាគីត្រូវបានពង្រឹង ដើម្បីផលប្រយោជន៍សេដ្ឋកិច្ចកម្ពុជា

៤. ការអនុវត្តការងារការទូតសេដ្ឋកិច្ចកម្ពុជាត្រូវបានលើកកម្ពស់

៥. ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសអនុវត្តត្រូវបានបន្តអនុវត្ត

**រយៈពេលរំពឹងទុក៖ ខែមករា - ធ្នូ ឆ្នាំ២០២២**

| សកម្មភាព | សូចនាករគន្លឹះ | លទ្ធផលរំពឹងទុក | តួនាទី និងទំនួលខុសត្រូវ | រយៈពេល (ត្រីមាស) | | | | គម្រោងថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|
| | | | | ទី១ | ទី២ | ទី៣ | ទី៤ | |
| ២.១. បង្កើតកម្មវិធីចែកចាយព័ត៌មាន ដើម្បីរក្សាទុក និងចែកចាយបន្ត<br>លទ្ធផលគន្លឹះ៖<br>• បានបង្កើតកម្មវិធីរក្សាទុក និងចែករំលែកព័ត៌មានការទូតសេដ្ឋកិច្ច<br>• បានបន្តធ្វើបច្ចុប្បន្នភាព និងចែករំលែកផ្ទាំងផ្តល់ព័ត៌មាន | | | | | | | | ២ ៣០០ |
| ២.១.១. បង្កើតកម្មវិធីរក្សាទុក និងចែករំលែកព័ត៌មាន | • កម្មវិធីឌីជីថលដែលមានទម្រង់ច្បាស់លាស់ | • កម្មវិធីឌីជីថលត្រូវបានបង្កើត ដើម្បីរក្សាទុក និងចែករំលែកព័ត៌មានការទូតសេដ្ឋកិច្ច | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• នាយកដ្ឋានព័ត៌មានវិទ្យា | ត្រីមាសទី១-៤ | | | | ២ ០០០ |
| ២.១.២. ប្រមូល ចែករំលែក និងធ្វើបច្ចុប្បន្នភាពព័ត៌មានសេដ្ឋកិច្ចនៅក្នុងកម្មវិធីរក្សាទុក និងចែករំលែកផ្ទាំងផ្តល់ព័ត៌មាន | • តំណរភ្ជាប់ និងគេហទំព័រ<br>• ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅលើផ្ទាំងផ្តល់ព័ត៌មាន<br>• ចំនួនតំណរភ្ជាប់<br>• ចំនួនអ្នកចូលមើលគេហទំព័រ | • តំណរភ្ជាប់ គេហទំព័រ ផ្ទាំងផ្តល់ព័ត៌មាន។ល។ ត្រូវបានបន្តធ្វើបច្ចុប្បន្នភាព<br>• កម្មវិធីចែករំលែកព័ត៌មានត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• នាយកដ្ឋានព័ត៌មានវិទ្យា<br>• ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>• ដៃគូរដ្ឋ និងវិស័យឯកជនពាក់ព័ន្ធ | ត្រីមាសទី១-៤ | | | | ៣០០ |

| | | | | | |
|---|---|---|---|---|---|
| ២.២. បន្តការបណ្តុះបណ្តាលស្តីពីការទូតសេដ្ឋកិច្ចដល់អ្នកការទូតកម្ពុជា និងភាគីពាក់ព័ន្ធ<br>លទ្ធផលគន្លឹះ៖<br>• បានធ្វើបច្ចុប្បន្នភាពការវាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស<br>• បានធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាល<br>• បានបន្តវាយតម្លៃសមត្ថភាព និងការបណ្តុះបណ្តាលជំនាញការទូតសេដ្ឋកិច្ចដល់អ្នកការទូត និងភាគីពាក់ព័ន្ធ<br>• បានលើកកម្ពស់ការអនុវត្តការងារការទូតសេដ្ឋកិច្ចតាមរយៈកិច្ចសហការជាមួយភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព និងចូលរួមកាន់តែសកម្មក្នុងសកម្មភាពលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ចជាតិ | | | | | ៧០០ |
| ២.២.១. ធ្វើបច្ចុប្បន្នភាពការវាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស | • របាយការណ៍វាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស | • បានធ្វើបច្ចុប្បន្នភាពរបាយ-ការណ៍វាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>• នាយកដ្ឋានបុគ្គលិក<br>• នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី១ | ៥០ |
| ២.២.២. ធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាល | • រយៈពេលនៃវគ្គបណ្តុះបណ្តាល<br>• ប្រភេទ និងចំនួនកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកការទូត និងភាគីពាក់ព័ន្ធ | • កម្មវិធីបណ្តុះបណ្តាលត្រូវបានបង្កើតជាច់ដោយឡែកពីគ្នាសម្រាប់អ្នកការទូត (ឯកអគ្គ-រាជទូត កុងស៊ុល និងកុងស៊ុលកិត្តិយស) និងភាគីពាក់ព័ន្ធ<br>• ខ្លឹមសារនៃវគ្គបណ្តុះបណ្តាលត្រូវបានធ្វើបច្ចុប្បន្នភាពឱ្យសមស្របនឹងស្ថានភាពបច្ចុប្បន្ន | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>• នាយកដ្ឋានបុគ្គលិក<br>• នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី១-៤ | ៥០ |

| | | | | | |
|---|---|---|---|---|---|
| ២.២.៣. ការបណ្ដុះបណ្ដាល | •រយៈពេលនៃវគ្គបណ្ដុះបណ្ដាល<br>•ចំនួនអ្នកការទូត | •អ្នកការទូតត្រូវបានបណ្ដុះបណ្ដាលប្រកបដោយវិជ្ជាជីវៈ<br>•អ្នកការទូតមានសមត្ថភាពក្នុងការចែករំលែកបទពិសោធន៍ ចំណេះដឹង និងចំណេះធ្វើស្ដីពីការទូតសេដ្ឋកិច្ច | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>•នាយកដ្ឋានបុគ្គលិក<br>•នាយកដ្ឋានពាក់ព័ន្ធ<br>•ក្រសួង និងស្ថាប័នពាក់ព័ន្ធ | ត្រីមាសទី១-៤ | ៦០០ |
| ២.៣. ពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកិច្ចសន្ទនាពហុភាគី ដើម្បីផលប្រយោជន៍សេដ្ឋកិច្ចកម្ពុជា<br>លទ្ធផលគន្លឹះ៖<br>• បានពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកិច្ចសន្ទនាពហុភាគី តាមរយៈសកម្មភាពការទូតសេដ្ឋកិច្ច<br>• បានពង្រីកផលប្រយោជន៍សេដ្ឋកិច្ចជាតិតាមរយៈភាពជាដៃគូរឹងមាំ និងកិច្ចសន្ទនាដ៏ផុលផុស | | | | | ៤០០ |
| ២.៣.១. បន្តពង្រឹងភាពជាដៃគូ រវាងរដ្ឋ និងវិស័យឯកជនតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់ការទូតសេដ្ឋកិច្ច | •ចំនួនសកម្មភាពដែលបានសហការរៀបចំក្នុងមួយឆ្នាំ<br>•ចំនួនកាលានុវត្តភាពសេដ្ឋកិច្ច និងគម្រោងវិនិយោគដែលទទួលបានក្នុងមួយឆ្នាំ<br>•របាយការណ៍ការងារចុងឆ្នាំ | •ការសហការរវាងរដ្ឋ និងវិស័យឯកជនត្រូវបានពង្រឹង<br>•កាលានុវត្តភាពពាណិជ្ជកម្ម<br>•វិនិយោគ និងការងារថ្មីៗត្រូវបានបង្កើតបន្ថែម<br>•ធាតុចូលពីវិស័យឯកជនត្រូវបានប្រមូល និងចែករំលែក | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•ក្រសួង និងស្ថាប័នពាក់ព័ន្ធ<br>•ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>•នាយកដ្ឋានហិរញ្ញវត្ថុ<br>•នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី១-៤ | ២០០ |

| | | | | | |
|---|---|---|---|---|---|
| ២.៣.២. បន្តស្វែងរកកាលានុវត្តភាពសេដ្ឋកិច្ច និងសហការជាមួយដៃគូទ្វេភាគី និងពហុភាគី តាមរយៈការផ្សព្វផ្សាយ និងការចរចាពាណិជ្ជកម្ម | •របាយការណ៍វឌ្ឍនភាពការងារ | •កាលានុវត្តភាពសេដ្ឋកិច្ចថ្មីៗត្រូវបានបង្កើត<br>•បានបន្តលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ ក្នុងកម្រិតទ្វេភាគី និងពហុភាគី<br>•បានទទួលគម្រោងពាណិជ្ជកម្ម និងវិនិយោគថ្មីៗ<br>•បានចូលរួមកាន់តែច្រើនក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•ក្រសួង និងស្ថាប័នពាក់ព័ន្ធ<br>•ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>•នាយកដ្ឋានហិរញ្ញវត្ថុ | ត្រីមាសទី១-៤ | ២០០ |
| **២.៤. លើកកម្ពស់ការអនុវត្តការងារការទូតសេដ្ឋកិច្ចកម្ពុជា**<br>**លទ្ធផលគន្លឹះ៖**<br>• បានបន្តសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ចជាតិ<br>• បានបន្តរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស និងទេសចរណ៍ | | | | | ២ ០០០ |
| ២.៤.១. បន្តសហការជាមួយដៃគូ និងស្ថាប័នគន្លឹះ | •វេទិកាពិភាក្សារវាងអ្នកការទូត និងភាគីពាក់ព័ន្ធ ដើម្បីផ្លាស់ប្តូរយោបល់ និងចែករំលែកបទពិសោធន៍ ឧត្តមានុវត្តន៍ ដំណោះស្រាយ ឬអនុសាសន៍ទៅលើបញ្ហាប្រឈម | •ភាគីទំនាក់ទំនងរបស់ស្ថានបេសកកម្មនៅបរទេស និងក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ចបានបន្តសហការកាន់តែសកម្មជាមួយដៃគូ ឬភាគីពាក់ព័ន្ធគន្លឹះ<br>•មតិត្រលប់ ឧត្តមានុវត្តន៍ ដំណោះស្រាយ ឬអនុសាសន៍ត្រូវបានចងក្រងជាឯកសារ ដើម្បីជាមគ្គុទេសក៍សម្រាប់ការអនុវត្តការងារការទូតសេដ្ឋកិច្ចនៅដំណាក់កាលទី៣ | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>•នាយកដ្ឋានពាក់ព័ន្ធ<br>•ស្ថាប័ន និងភាគីពាក់ព័ន្ធ | ត្រីមាសទី១-៤ | ១ ០០០ |

| | | | | | |
|---|---|---|---|---|---|
| ២.៤.២. បន្តរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស និងទេសចរណ៍ | • របាយការណ៍សកម្មភាព សមិទ្ធផល និងវឌ្ឍនភាពការងារការទូតសេដ្ឋកិច្ច<br>• ចំនួនកិច្ចសហការជាមួយដៃគូ និងស្ថាប័នគន្លឹះ | • កិច្ចសហការជាមួយដៃគូ និងស្ថាប័នគន្លឹះបានរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស និងទេសចរណ៍<br>• កិច្ចសហការជាមួយដៃគូ និងស្ថាប័នគន្លឹះគឺប្រកបដោយចីរភាព និងបង្កើតអត្ថប្រយោជន៍ទៅវិញទៅមក | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>• នាយកដ្ឋានពាក់ព័ន្ធ<br>• ស្ថាប័ន និងភាគីពាក់ព័ន្ធ | ត្រីមាសទី១-៤ | ១ ០០០ |
| **២.៥. បន្តតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសអនុវត្ត**<br>**លទ្ធផលគន្លឹះ៖**<br>• បានលើកកម្ពស់ការអនុវត្តការងារការទូតសេដ្ឋកិច្ចតាមរយៈការយល់ដឹងកាន់តែច្បាស់ និងចូលរួមកាន់តែសកម្មក្នុងសកម្មភាពលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ចជាតិ | | | | | ១០០ |
| ២.៥.១. លទ្ធផលមតិត្រលប់ និងរបាយការណ៍វាយតម្លៃការអនុវត្តការងារ | • ការធ្វើតេស្តសមត្ថភាពមុន និងក្រោយវគ្គបណ្តុះបណ្តាល<br>• មតិត្រលប់ពីអ្នកការទូត មន្ត្រីអនុវត្ត ភាគីពាក់ព័ន្ធ និងដៃគូពីរដ្ឋ និងវិស័យឯកជន<br>• មតិត្រលប់ពីគ្រូបង្គោល សិក្ខាកាម និងថ្នាក់លើរបស់សិក្ខាកាម<br>• ការវិភាគ ការស្រាវជ្រាវ ដំណោះស្រាយ ឬអនុសាសន៍ | • ការអនុវត្តការងារការទូតសេដ្ឋកិច្ចត្រូវបានលើកកម្ពស់<br>• បញ្ហាប្រឈមចម្បងៗត្រូវបានដោះស្រាយ<br>• ផែនការសកម្មភាពសម្រាប់ដំណាក់កាលបន្ទាប់ត្រូវបានរៀបចំកាន់តែល្អប្រសើរ | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>• នាយកដ្ឋានពាក់ព័ន្ធ<br>• សវនកម្មផ្ទៃក្នុង ឬស្ថាប័នរដ្ឋ | ត្រីមាសទី៤ | ១០០ |

## ដំណាក់កាលទី៣ — គម្រោងថវិកាចំនួន ៥ ១០០លានរៀល

**គោលដៅរួមសម្រាប់ដំណាក់កាលទី៣៖ បង្កើនចំនួនមន្ត្រីការទូតសេដ្ឋកិច្ចប្រកបដោយសមត្ថភាព និងវិជ្ជាជីវៈ**

**លទ្ធផលរំពឹងទុក៖**

១. ការបណ្តុះបណ្តាលស្តីពីការទូតសេដ្ឋកិច្ចដល់អ្នកការទូតកម្ពុជា និងភាគីពាក់ព័ន្ធត្រូវបានបន្តអនុវត្ត

២. យន្តការដើម្បីគាំទ្រដល់កម្មវិធីចែកចាយព័ត៌មានសម្រាប់ការអនុវត្តការទូតសេដ្ឋកិច្ចត្រូវបានបន្តអភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់

៣. ការអនុវត្តការងារការទូតសេដ្ឋកិច្ចត្រូវបានបន្តលើកកម្ពស់

៤. សមិទ្ធកម្មយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ ត្រូវបានសរុប និងវាយតម្លៃ

៥. យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២៤-២០២៨ ត្រូវបានរៀបចំ

**រយៈពេលរំពឹងទុក៖ ខែមករា - ធ្នូ ឆ្នាំ២០២៣**

| សកម្មភាព | សូចនាករគន្លឹះ | លទ្ធផលរំពឹងទុក | តួនាទី និងទំនួលខុសត្រូវ | រយៈពេល (ត្រីមាស) | | | | គម្រោងថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|
| | | | | ទី១ | ទី២ | ទី៣ | ទី៤ | |
| ៣.១. បន្តការបណ្តុះបណ្តាលស្តីពីការទូតសេដ្ឋកិច្ចដល់អ្នកការទូតកម្ពុជា និងភាគីពាក់ព័ន្ធ<br>លទ្ធផលគន្លឹះ៖<br>• បានធ្វើបច្ចុប្បន្នភាពការវាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស<br>• បានធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាល<br>• បានបន្តវាយតម្លៃសមត្ថភាព និងបណ្តុះបណ្តាលជំនាញការទូតសេដ្ឋកិច្ចដល់អ្នកការទូត និងភាគីពាក់ព័ន្ធ | | | | | | | | ៨០០ |
| ៣.១.១. ធ្វើបច្ចុប្បន្នភាពការវាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស | •របាយការណ៍វាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្ស | •របាយការណ៍វាយតម្លៃតម្រូវការលើការអភិវឌ្ឍធនធានមនុស្សត្រូវបានធ្វើបច្ចុប្បន្នភាព | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>•នាយកដ្ឋានបុគ្គលិក<br>•នាយកដ្ឋានពាក់ព័ន្ធ | ត្រីមាសទី១ | | | | ៥០ |
| ៣.១.២.ធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាល | •រយៈពេលនៃវគ្គបណ្តុះបណ្តាល<br>•ប្រភេទ និងចំនួនកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកការទូត និងភាគីពាក់ព័ន្ធ | •កម្មវិធីបណ្តុះបណ្តាលត្រូវបានបង្កើតជាចំដោយឡែកពីគ្នាសម្រាប់អ្នកការទូត (ឯកអគ្គរាជទូត កុងស៊ុល និងកុងស៊ុលកិត្តិយស) និងភាគីពាក់ព័ន្ធ<br>•ខ្លឹមសារនៃវគ្គបណ្តុះបណ្តាលត្រូវបានធ្វើបច្ចុប្បន្នភាពឱ្យសមស្របនឹងស្ថានភាពបច្ចុប្បន្ន<br>•អ្នកការទូត និងភាគីពាក់ព័ន្ធមានសមត្ថភាពអនុវត្តការងារការទូតសេដ្ឋកិច្ច | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>•នាយកដ្ឋានបុគ្គលិក<br>•នាយកដ្ឋានពាក់ព័ន្ធ<br>•ក្រសួង និងស្ថាប័នពាក់ព័ន្ធ | ត្រីមាសទី១-៤ | | | | ៥០ |

| | | | | | |
|---|---|---|---|---|---|
| ៣.១.៣. ការបណ្ដុះបណ្ដាល | • រយៈពេលនៃវគ្គបណ្ដុះបណ្ដាល<br>• ចំនួនអ្នកការទូត<br>• ការអភិវឌ្ឍសម្ភារៈគរុកោសល្យ និងបណ្ដុះបណ្ដាល | • អ្នកការទូតត្រូវបានបណ្ដុះបណ្ដាលប្រកបដោយវិជ្ជាជីវៈ<br>• អ្នកការទូតមានសមត្ថភាពក្នុងការចែករំលែកបទពិសោធន៍ ចំណេះដឹង និងចំណេះធ្វើស្ដីពីការទូតសេដ្ឋកិច្ច | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>• នាយកដ្ឋានបុគ្គលិក<br>• នាយកដ្ឋានពាក់ព័ន្ធ<br>• ក្រសួង និងស្ថាប័នពាក់ព័ន្ធ | ត្រីមាសទី១-៤ | ៧០០ |
| ៣.២. បន្តអភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់នូវយន្តការគាំទ្រកម្មវិធីចែកចាយព័ត៌មានសម្រាប់ការអនុវត្តការទូតសេដ្ឋកិច្ច<br>លទ្ធផលគន្លឹះ៖<br>• បានបង្កើតយន្តការចែករំលែកព័ត៌មានដែលងាយស្រួលប្រើប្រាស់<br>• បានលើកកម្ពស់ការអនុវត្តការងារការទូតសេដ្ឋកិច្ច | | | | | ៤០០ |
| ៣.២.១. បង្កើតយន្តការថ្មីៗដែលជួយសម្រួលដល់ការប្រើប្រាស់ និងចែករំលែកព័ត៌មាន | • យន្តការថ្មីៗដែលជួយសម្រួលការទំនាក់ទំនង<br>• កម្មវិធីឌីជីថលផ្សេងៗ | • កម្មវិធីឌីជីថលដែលជួយសម្រួលការទំនាក់ទំនងត្រូវបានធ្វើបច្ចុប្បន្នភាព<br>• យន្តការ និងបណ្ដាញចែករំលែកព័ត៌មានទំនាក់ទំនងត្រូវបានបង្កើត និងធ្វើបច្ចុប្បន្នភាព | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• នាយកដ្ឋានព័ត៌មានវិទ្យា<br>• ភាគីពាក់ព័ន្ធ | ត្រីមាសទី១-៤ | ២០០ |
| ៣.២.២. ប្រើប្រាស់យន្តការចែករំលែកព័ត៌មានដែលទើបបង្កើតថ្មី | • របាយការណ៍វឌ្ឍនភាពការងារ<br>• ភាពញឹកញាប់នៃការប្រើប្រាស់យន្តការថ្មី | • ការចែករំលែកព័ត៌មានមានប្រសិទ្ធភាពជាងមុន<br>• ការទំនាក់ទំនងមានប្រសិទ្ធភាពជាងមុន<br>• ការអនុវត្តការងារការទូតសេដ្ឋកិច្ចមានប្រសិទ្ធភាពជាងមុន តាមរយៈការប្រើប្រាស់យន្តការថ្មី | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• នាយកដ្ឋានព័ត៌មានវិទ្យា<br>• ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>• ភាគីពាក់ព័ន្ធ | ត្រីមាសទី២-៤ | ២០០ |

| | | | | | |
|---|---|---|---|---|---|
| ៣.៣. បន្តលើកកម្ពស់ការអនុវត្តការងារការទូតសេដ្ឋកិច្ច<br>លទ្ធផលគន្លឹះ៖<br>• បានបន្តសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ចជាតិ<br>• បានបន្តរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស និងទេសចរណ៍ | | | | | ៣ ០០០ |
| ៣.៣.១. បន្តសហការជាមួយដៃគូ និងស្ថាប័នគន្លឹះ | •វេទិកាពិភាក្សារវាងអ្នកការទូត និងភាគីពាក់ព័ន្ធ ដើម្បីផ្លាស់ប្តូរយោបល់ និងចែករំលែកបទពិសោធន៍ឧត្តមានុវត្តន៍ ដំណោះស្រាយ ឬអនុសាសន៍ទៅលើបញ្ហាប្រឈម | •ភាគីទំនាក់ទំនងរបស់ស្ថានបេសកកម្មនៅបរទេស និងក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ចបានបន្តសហការកាន់តែសកម្មជាមួយដៃគូ ឬភាគីពាក់ព័ន្ធគន្លឹះ<br>•មតិត្រលប់ ឧត្តមានុវត្តន៍ ដំណោះស្រាយ ឬអនុសាសន៍ត្រូវបានចងក្រងជាឯកសារ ដើម្បីជាមគ្គុទេសក៍សម្រាប់ការអនុវត្តការងារការទូតសេដ្ឋកិច្ចនៅដំណាក់កាលបន្ទាប់ | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>•នាយកដ្ឋានពាក់ព័ន្ធ<br>•ស្ថាប័ន និងភាគីពាក់ព័ន្ធ | ត្រីមាសទី១-៤ | ១ ៥០០ |
| ៣.៣.២. បន្តរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស និងទេសចរណ៍ | •របាយការណ៍សកម្មភាព សមិទ្ធផល និងវឌ្ឍនភាពការងារការទូតសេដ្ឋកិច្ច<br>•កិច្ចសហការជាមួយដៃគូ និងស្ថាប័នគន្លឹះដែលរួមចំណែកកាន់តែច្រើនដល់កំណើនសេដ្ឋកិច្ចជាតិ | •បានរួមចំណែកយ៉ាងសកម្មដល់កំណើនសេដ្ឋកិច្ច តាមរយៈការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស និងទេសចរណ៍<br>•កិច្ចសហការ និងការសម្របសម្រួលនានាគឺប្រកបដោយចីរភាព និងបន្ទុបង្កើតអត្ថ-ប្រយោជន៍ទៅវិញទៅមក | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>•នាយកដ្ឋានពាក់ព័ន្ធ<br>•ស្ថាប័ន និងភាគីពាក់ព័ន្ធ | ត្រីមាសទី១-៤ | ១ ៥០០ |

| | | | | | |
|---|---|---|---|---|---|
| ៣.៤. សរុប និងវាយតម្លៃសមិទ្ធកម្មយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣<br>លទ្ធផលគន្លឹះ៖<br>• បានសំយោគការវាយតម្លៃ មតិត្រលប់ និងអនុសាសន៍<br>• អ្នកការទូត និងភាគីពាក់ព័ន្ធមានជំនាញ សមត្ថភាព និងការតាំងចិត្តប្រសើរជាងមុន<br>• បានលើកកម្ពស់ការអនុវត្តការងារការទូតសេដ្ឋកិច្ច<br>• បានកំណត់វិស័យគន្លឹះក្នុងការអនុវត្តការងារការទូតសេដ្ឋកិច្ច | | | | | ២០០ |
| ៣.៤.១. សំយោគការវាយតម្លៃ មតិត្រលប់ និងអនុសាសន៍ | • របាយការណ៍នៃការវាយតម្លៃ មតិត្រលប់ និងអនុសាសន៍<br>• គម្រោង និងសកម្មភាពដែលបានចូលរួម | • ការវាយតម្លៃ មតិត្រលប់ និងអនុសាសន៍ត្រូវបានសំយោគ<br>• អ្នកការទូតសេដ្ឋកិច្ច និងភាគីពាក់ព័ន្ធមានជំនាញ សមត្ថភាព និងការតាំងចិត្តប្រសើរជាងមុន<br>• បានចូលរួមយ៉ាងសកម្មក្នុងគម្រោង ឬសកម្មភាពលើកកម្ពស់ការទូតសេដ្ឋកិច្ច<br>• ការអនុវត្តការងារការទូតសេដ្ឋកិច្ចត្រូវបានសម្របសម្រួល និងពង្រឹងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល<br>• បានចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជារួម | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>• នាយកដ្ឋានបុគ្គលិក<br>• នាយកដ្ឋានពាក់ព័ន្ធ<br>• ស្ថានបេសកកម្មកម្ពុជានៅបរទេស<br>• ក្រសួង និងស្ថាប័នពាក់ព័ន្ធ | ត្រីមាសទី២-៣ | ១០០ |
| ៣.៤.២. កំណត់វិស័យគន្លឹះក្នុងការអនុវត្តការងារការទូតសេដ្ឋកិច្ច ដើម្បីជំរុញកំណើនសេដ្ឋកិច្ច | • ការសំយោគរបាយការណ៍ និងអនុសាសន៍<br>• គម្រោង និងសកម្មភាពដែលបានចូលរួម | • វិស័យគន្លឹះក្នុងការអនុវត្តការងារការទូតសេដ្ឋកិច្ចត្រូវបានកំណត់ និងវាយតម្លៃ<br>• ឧត្តមានុវត្តន៍តាមវិស័យត្រូវបានកត់ត្រាទុក និងចែករំលែក | • ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>• នាយកដ្ឋានបុគ្គលិក<br>• នាយកដ្ឋានពាក់ព័ន្ធ<br>• ស្ថានបេសកកម្មកម្ពុជានៅបរទេស | ត្រីមាសទី២-៣ | ១០០ |

| ៣.៥. រៀបចំយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២៤-២០២៨<br>លទ្ធផលគន្លឹះ៖<br>• បានរៀបចំរបាយការណ៍វាយតម្លៃតម្រូវការ ដើម្បីរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៤-២០២៨<br>• បានរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៤-២០២៨<br>• បានរៀបចំសិក្ខាសាលា ដើម្បីប្រមូលធាតុចូលពីក្រសួង និងភាគីពាក់ព័ន្ធ<br>• បានបញ្ចប់ និងអនុម័តសេចក្តីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៤-២០២៨ | | | | | ៧០០ |
|---|---|---|---|---|---|
| ៣.៥.១. ធ្វើការវាយតម្លៃតម្រូវការ | •របាយការណ៍វាយតម្លៃតម្រូវការ | •ការវាយតម្លៃតម្រូវការត្រូវបានរៀបចំជារបាយការណ៍ | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>•នាយកដ្ឋានបុគ្គលិក<br>•នាយកដ្ឋានពាក់ព័ន្ធ<br>•ក្រសួង និងស្ថាប័នពាក់ព័ន្ធ | ត្រីមាសទី១-៣ | ២០០ |
| ៣.៥.២. រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៤-២០២៨ | •សេចក្តីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៤-២០២៨ | •សេចក្តីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៤-២០២៨ ត្រូវបានរៀបចំ | •ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច<br>•វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ<br>•នាយកដ្ឋានបុគ្គលិក<br>•នាយកដ្ឋានពាក់ព័ន្ធ<br>•ក្រសួង និងស្ថាប័នពាក់ព័ន្ធ | ត្រីមាសទី២-៣ | ២០០ |

| | | | | | |
|---|---|---|---|---|---|
| ៣.៥.៣. រៀបចំសិក្ខាសាលា ដើម្បីប្រមូល និងសំយោគ ធាតុចូលពីបណ្ដាស្ថាប័ន សំខាន់ៗ និងភាគីពាក់ព័ន្ធ ដើម្បីព្រាងយុទ្ធសាស្ត្រ ការទូតសេដ្ឋកិច្ច ឆ្នាំ២០២៤-២០២៨ | • របាយការណ៍សិក្ខាសាលា<br>• ធាតុចូល ដើម្បីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២៤-២០២៨ | • សិក្ខាសាលាត្រូវបានរៀបចំ<br>• ធាតុចូលពីបណ្ដាក្រសួងសំខាន់ៗ និងភាគីពាក់ព័ន្ធ ត្រូវបានប្រមូល និងសំយោគទៅក្នុងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៤-២០២៨ | • កបទ.សអ<br>• ក្រសួង និងស្ថាប័នពាក់ព័ន្ធ<br>• ស្ថាប័នរដ្ឋ និងវិស័យឯកជន<br>• ភាគីពាក់ព័ន្ធ | ត្រីមាសទី៤ | ១០០ |
| ៣.៥.៤. បញ្ចប់ និងអនុម័ត សេចក្ដីព្រាងយុទ្ធសាស្ត្រ ការទូតសេដ្ឋកិច្ច ឆ្នាំ២០២៤-២០២៨ | • សេចក្ដីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២៤-២០២៨ | • ព័ត៌មានត្រូវបានវាយតម្លៃ និងសំយោគទៅក្នុងសេចក្ដីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២៤-២០២៨<br>• សេចក្ដីព្រាងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៤-២០២៨ ត្រូវបានបញ្ចប់ និងអនុម័ត<br>• សិក្ខាសាលាផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២៤-២០២៨ ត្រូវបានរៀបចំ | • កបទ.សអ<br>• ក្រសួង និងស្ថាប័នពាក់ព័ន្ធ | ត្រីមាសទី៣-៤ | ២០០ |

# ឧបសម្ព័ន្ធទី២៖
## អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការការបរទេស

- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីការចាត់តាំង និងការប្រព្រឹត្តទៅនៃប្រព័ន្ធសម្របសម្រួលផ្ទៃក្នុង
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតអង្គភាពជាតិសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងដូចខាងក្រោម៖

- កំណត់បេសកកម្ម និងរៀបចំចេនាសម្ព័ន្ធរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- កំណត់មុខងារ និងភារកិច្ចរបស់អង្គភាពនានានៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលការងារក្នុងវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនិងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ដោយគ្របដណ្តប់លើវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា ៤.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំ និងគ្រប់គ្រងវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៥.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សេចក្ដីថ្លៃថ្នូរ និងកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា
- រៀបចំ អនុវត្ត តាមដានការអនុវត្ត និងការពារគោលនយោបាយនិងផែនការយុទ្ធសាស្ត្រការបរទេសរបស់រាជរដ្ឋាភិបាលកម្ពុជា
- រៀបចំ អនុវត្ត និងតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ឬលិខិតូបករណ៍អន្តរជាតិក្នុងន័យធានានិងការពារផលប្រយោជន៍របស់រាជរដ្ឋាភិបាលក្នុងកិច្ចការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ជាច្រកចេញចូលការទូតតែមួយក្នុងទំនាក់ទំនងជាមួយប្រទេសនិងអង្គការតំបន់ និងស្ថាប័នអន្តរជាតិនានាលើរាល់សកម្មភាពរបស់ក្រសួងស្ថាប័ននានាដែលមានទំនាក់ទំនងជាមួយបរទេស
- តំណាងរាជរដ្ឋាភិបាលកម្ពុជាក្នុងការចរចា និងធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីជាមួយបណ្ដាប្រទេស អង្គការតំបន់ និងស្ថាប័នអន្តរជាតិនានា
- ពង្រឹងនិងពង្រីកទំនាក់ទំនង រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេស អង្គការតំបន់ និងអង្គការអន្តរជាតិនានា តាមរយៈកិច្ចការការទូត កុងស៊ុល និងសហប្រតិបត្តិការអន្តរជាតិ
- ពង្រឹងវិស័យការទូតសេដ្ឋកិច្ចតាមរយៈការចូលរួមជំរុញវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ធុរកិច្ច ទេសចរណ៍ ការងារ អប់រំ និងបច្ចេកវិទ្យា
- ផ្សព្វផ្សាយនិងលើកតម្កើងភាសា វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរនៅក្រៅប្រទេស
- ចូលរួមការពារនិងរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ នៅថ្នាក់អនុតំបន់ តំបន់ និងពិភពលោក
- ចូលរួម និងទទួលរៀបចំកិច្ចប្រជុំថ្នាក់អនុតំបន់ តំបន់ និងពិភពលោកពាក់ព័ន្ធនឹងកិច្ចការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឬតាមការចាត់តាំងរបស់រាជរដ្ឋាភិបាល
- តំណាងនិងការពារផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋខ្មែរទាំងរូបវន្តបុគ្គលនិងនីតិបុគ្គល ព្រមទាំងលើកកម្ពស់ និងការពារកិត្តិយសជាតិ ស្របតាមច្បាប់ជាតិ និងអន្តរជាតិ
- ដឹកនាំគ្រប់គ្រងស្ថានតំណាងរបស់ព្រះរាជាណាចក្រកម្ពុជាដែលតាំងនៅបរទេស

៣

- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការចុះបញ្ជី និងសហការសម្របសម្រួលការធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់ស្ថានតំណាងបរទេស ស្ថានតំណាងស្ថាប័នអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបរទេស ដោយយោងតាមច្បាប់ជាតិនិងអន្តរជាតិ
- សម្របសម្រួលនិងរៀបចំទស្សនកិច្ចរបស់គណៈប្រតិភូរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទៅបរទេស និងទទួលគណៈប្រតិភូបរទេសដែលមកបំពេញបេសកកម្មឬទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា
- បណ្តុះបណ្តាលនិងធ្វើក្រឹតការជាប្រចាំនូវមុខជំនាញកិច្ចការបរទេស និងការទូត
- តាមដាន ស្វែងយល់ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការវិវត្តនៃព្រឹត្តិការណ៍តំបន់ និងអន្តរជាតិសំខាន់ៗ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់រាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា ៦.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

ក- អង្គភាពរដ្ឋបាលកណ្តាល

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានអាស៊ាន
- អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន
- អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក
- អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- អគ្គាធិការដ្ឋាន
- វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ
- នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ខ-ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

- ស្ថានឯកអគ្គរាជទូតនិងស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការតំបន់ និងអង្គការអន្តរជាតិ
- ស្ថានអគ្គកុងស៊ុលនិងស្ថានកុងស៊ុល
- ស្ថានកុងស៊ុលកិត្តិយស។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងមួយចំនួនតាមការចាំបាច់។

វិទ្យាស្ថាន ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមួយចំនួនមានឋានៈស្មើអគ្គនាយករង តាមការចាំបាច់។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។

អង្គការលេខរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៨.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថានជាតិនិងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៩.-**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី៤
## អគ្គលេខាធិការដ្ឋាន

**មាត្រា ១០.-**

អគ្គលេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលើបេសកកម្មគ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង និងសម្របសម្រួលការងារពាក់ព័ន្ធពិធីការរដ្ឋ។

**មាត្រា ១១.-**

អគ្គលេខាធិការដ្ឋានមានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង និងត្រួតពិនិត្យការចេញចូលឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង
- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលនៅគ្រប់ថ្នាក់ និងគ្រប់ផ្នែកនៅក្រោមសមត្ថកិច្ចរបស់ក្រសួង និងរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលជាមួយបណ្ដាក្រសួង ស្ថាប័ន និងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- គ្រប់គ្រង និងត្រួតពិនិត្យការងារផែនការហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ និងបញ្ជីសារពើភណ្ឌ
- ពិនិត្យ និងសម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង និងបូកសរុបរបាយការណ៍ហិរញ្ញវត្ថុនិងសកម្មភាពការងាររបស់ក្រសួង
- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិករបស់ក្រសួង
- សិក្សានិងវាយតម្លៃតម្រូវការសម្រាប់ការកសាងសមត្ថភាពធនធានមនុស្សនិងការបង្កើនគុណភាពវិជ្ជាជីវៈផ្នែកការបរទេសនិងសហប្រតិបត្តិការអន្តរជាតិដោយសហការជាមួយវិទ្យាស្ថានជាតិទំនាក់ទំនងការទូតនិងសិក្សាអន្តរជាតិ
- ចូលរួមរៀបចំសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនៅក្រោមសមត្ថកិច្ចរបស់ក្រសួង
- អនុវត្តគោលការណ៍ស្ដីពីពិធីការការទូតតាមវិធាននិងទំនៀមទម្លាប់របស់ព្រះរាជាណាចក្រកម្ពុជា និងតាមវិធីនិងទម្លាប់អន្តរជាតិ
- សម្របសម្រួលនិងសហការរៀបចំកម្មវិធីទស្សនកិច្ចរបស់ ថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ និងដំណើរបំពេញទស្សនកិច្ចរបស់គណប្រតិភូថ្នាក់ដឹកនាំជាន់ខ្ពស់បរទេសនៅព្រះរាជាណាចក្រកម្ពុជា
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
- អនុវត្តភារកិច្ចផ្សេងៗដែលក្រសួងប្រគល់ឱ្យ។

**មាត្រា ១២.-**

អគ្គលេខាធិការដ្ឋានមាននាយកដ្ឋានចំណុះចំនួន ០៤(បួន) ជាសេនាធិការ៖

- នាយកដ្ឋានរដ្ឋបាល : មានមុខងារសម្របសម្រួលការងារទូទៅរបស់ក្រសួងនៅថ្នាក់កណ្ដាល និងរវាងថ្នាក់កណ្ដាលជាមួយស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- នាយកដ្ឋានហិរញ្ញវត្ថុ-គណនេយ្យ : មានមុខងារសម្របសម្រួលការងារហិរញ្ញវត្ថុ និងគណនេយ្យ
- នាយកដ្ឋានបុគ្គលិក : មានមុខងារសម្របសម្រួលការងារគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ និងការងារបណ្ដុះបណ្ដាល
- នាយកដ្ឋានពិធីការ : មានមុខងារសម្របសម្រួលការងារពិធីការ។

## ជំពូកទី៥

## អគ្គនាយកដ្ឋានអាស៊ាន

**មាត្រា ១៣.-**

អគ្គនាយកដ្ឋានអាស៊ាន បំពេញមុខងារជាសេនាធិការឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាសេនាធិការឲ្យលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា ដោយធ្វើការងារសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់តំបន់ លើបេសកកម្មពាក់ព័ន្ធនឹងកិច្ចការអាស៊ាន ។

**មាត្រា ១៤.-**

អគ្គនាយកដ្ឋានអាស៊ានមានភារកិច្ច ដូចតទៅ៖

- សម្របសម្រួលរាល់កិច្ចការពាក់ព័ន្ធនឹងអាស៊ាន និងការអនុវត្តនូវកាតព្វកិច្ចនានា ដែលមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន និងសេចក្ដីសម្រេចនានារបស់អាស៊ាន នៅថ្នាក់ជាតិជាមួយនឹងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា
- សម្របសម្រួលរាល់កិច្ចការអាស៊ានក្នុងកម្រិតតំបន់និងធ្វើទំនាក់ទំនងជាអន្តរជាតិជាមួយលេខាធិការដ្ឋានជាតិអាស៊ាន នៃបណ្ដាប្រទេសសមាជិកអាស៊ាន លេខាធិការដ្ឋានអាស៊ាន ប្រទេសក្រៅតំបន់អាស៊ាន អង្គការតំបន់និងអន្តរជាតិជាដៃគូ និងអង្គភាពនានារបស់អាស៊ាន ក្នុងឋានៈជាសេនាធិការឲ្យលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា
- តាមដាន ត្រួតពិនិត្យ វាយតម្លៃនិងលើកយោបល់លើបញ្ហាពាក់ព័ន្ធនឹងមុខងារ និងដំណើរការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអាស៊ាន និងគ្រឹះស្ថានអាស៊ាន
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័ននានាលើការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលពាក់ព័ន្ធ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននិងកិច្ចប្រជុំអាស៊ានពាក់ព័ន្ធដទៃទៀត
- សិក្សា ស្រាវជ្រាវ និងតាមដានការវិវឌ្ឍនៃបញ្ហាសំខាន់ៗ ជាពិសេសផ្នែកនយោបាយ-សន្តិសុខ ព្រមទាំងរៀបចំជំនួយស្មារតី និងឯកសារទស្សនទានជូនថ្នាក់ដឹកនាំ ស្ដីពីគោលជំហររបស់កម្ពុជាលើកិច្ចការសហគមន៍នយោបាយ-សន្តិសុខអាស៊ាន និងទំនាក់ទំនងខាងក្រៅរបស់អាស៊ានជាមួយប្រទេសជាដៃគូសន្ទនាទាំងអស់ និងអង្គការតំបន់នានា
- ផ្ដួចផ្ដើមគំនិត និងផ្ដល់អនុសាសន៍ពាក់ព័ន្ធនឹងការកសាងសហគមន៍អាស៊ាន ការកសាងសហគមន៍អាស៊ីបូព៌ា និងវឌ្ឍនភាពនៃនិម្មាបនកម្មតំបន់
- ចូលរួមកិច្ចប្រជុំអាស៊ាន និងសិក្សា តាមដាន និងផ្ដល់យោបល់លើឯកសារពាក់ព័ន្ធក្នុងក្របខ័ណ្ឌអាស៊ាន និងឯកសារពាក់ព័ន្ធដទៃទៀតរវាងអាស៊ានជាមួយនឹងអង្គការតំបន់ និងអន្តរជាតិ

៧

- ធ្វើការកៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីសហគមន៍អាស៊ាន បណ្ដាប្រទេសសមាជិកអាស៊ាន និងប្រទេសដៃគូរបស់អាស៊ាន ព្រមទាំងជួយជំរុញការវិនិយោគទុនផ្ទាល់បរទេស និងអ្នកទេសចរណ៍មកកម្ពុជា ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា
- តាមដានការប្រើប្រាស់មូលនិធិរបស់អាស៊ាន និងមូលនិធិនៃកិច្ចសហប្រតិបត្តិការរវាងអាស៊ាននិងប្រទេសដៃគូសន្ទនា ព្រមទាំងធ្វើការសម្របសម្រួល និងជួយដល់ក្រសួង-ស្ថាប័ននានា ក្នុងការរៀបចំ និងអនុវត្តគម្រោងសកម្មភាពនានាក្នុងក្របខ័ណ្ឌអាស៊ាន
- រៀបចំផែនការការងារប្រចាំឆ្នាំ ធ្វើរបាយការណ៍ស្ដីពីសកម្មភាពអាស៊ាន និងរៀបចំថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការរបស់អគ្គនាយកដ្ឋាន រួមទាំងសម្រាប់ការរៀបចំនិងការចូលរួមកិច្ចប្រជុំអាស៊ាននានា និងសកម្មភាពដទៃទៀត ដូចជា ការបណ្ដុះបណ្ដាល ការស្រាវជ្រាវ និងការផ្សព្វផ្សាយការយល់ដឹងអំពីសហគមន៍អាស៊ាន
- តំកល់ព័ត៌មាន របាយការណ៍ និងឯកសារពាក់ព័ន្ធនឹងអាស៊ាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ឲ្យ និងតាមការសម្រេចរបស់កិច្ចប្រជុំលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា។

**មាត្រា ១៥.-**

អគ្គនាយកដ្ឋានអាស៊ាន មាននាយកដ្ឋានចំណុះចំនួន ០៥ (ប្រាំ) ជាសេនាធិការ៖

- នាយកដ្ឋានកិច្ចការទូទៅ និងសហគមន៍: មានមុខងារសម្របសម្រួលការងាររដ្ឋបាលទូទៅ ថវិកា និងកិច្ចការសហគមន៍
- នាយកដ្ឋានកិច្ចការសហគមន៍នយោបាយ-សន្តិសុខអាស៊ាន: មានមុខងារសម្របសម្រួលការងារសហគមន៍នយោបាយ-សន្តិសុខអាស៊ាន
- នាយកដ្ឋានកិច្ចការសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសង្គម-វប្បធម៌អាស៊ាន: មានមុខងារសម្របសម្រួលការងារសហគមន៍សេដ្ឋកិច្ច អាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន
- នាយកដ្ឋានទំនាក់ទំនងដៃគូសន្ទនាអាស៊ាន: មានមុខងារសម្របសម្រួលការងារទំនាក់ទំនងរវាងអាស៊ាន និងប្រទេសជាដៃគូសន្ទនារបស់អាស៊ាន
- នាយកដ្ឋានទំនាក់ទំនងអាស៊ានបូកបី និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា: មានមុខងារសម្របសម្រួលទំនាក់ទំនងរវាងអាស៊ានជាមួយប្រទេសបូកបី (ចិន-ជប៉ុន-សាធារណរដ្ឋកូរ៉េ) និងការងារកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។

## ជំពូកទី៦

## អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន

**មាត្រា១៦.-**

អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន បំពេញមុខងារជាសេនាធិការឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងបេសកកម្មពាក់ព័ន្ធនឹងកិច្ចការច្បាប់ កិច្ចការកុងស៊ុល និងកិច្ចការព្រំដែន។

**មាត្រា១៧.-**

អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការយុទ្ធសាស្ត្រនិងថវិកាសម្រាប់កិច្ចការច្បាប់ សន្ធិសញ្ញា កិច្ចការកុងស៊ុល និងកិច្ចការព្រំដែន
- លើកគម្រោងកសាងគោលនយោបាយច្បាប់ និងលិខិតបទដ្ឋានសម្រាប់បម្រើឲ្យវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចូលរួមរៀបចំពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលត្រូវបានរៀបចំដោយរាជរដ្ឋាភិបាល
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិចំពោះសន្ធិសញ្ញា កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីនិងការចូលជាភាគីនៃសន្ធិសញ្ញាអន្តរជាតិនានា
- ការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅបរទេស និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការគ្រប់គ្រងជនបរទេសនៅព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងផ្តល់ និងពន្យារសុពលភាពលិខិតឆ្លងដែនការទូត និងលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីរាជការ និងឥស្សរជនខ្មែរ
- គ្រប់គ្រងផ្តល់ និងពន្យារទិដ្ឋាការជូនជនបរទេស
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ក្នុងការការពារអធិបតេយ្យភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា តាមមធ្យោបាយការទូត និងក្នុងការគ្រប់គ្រងព្រំដែន នៃព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់ជាតិ និងអន្តរជាតិ
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធប្រយុទ្ធប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនព្រមទាំងអំពើជួញដូរ មនុស្ស អាវុធ និងគ្រឿងញៀន
- ធ្វើនីត្យានុកូលកម្មលើលិខិតស្នាមរបស់អាជ្ញាធរសាធារណៈ លើអត្ថបទបកប្រែលិខិតអត្រានុកូលដ្ឋាន និងឯកសារផ្សេងៗទៀតតាមការស្នើសុំរបស់ប្រជាពលរដ្ឋ
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀតដែលក្រសួងប្រគល់ឲ្យ។

៥

**មាត្រា១៨.-**

អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន មាននាយកដ្ឋានចំណុះចំនួន៣ (បី) ជាសេនាធិការ ៖

- នាយកដ្ឋានកិច្ចការច្បាប់និងសន្ធិសញ្ញា : មានមុខងារសម្របសម្រួលកិច្ចការច្បាប់ និងសន្ធិសញ្ញា
- នាយកដ្ឋានកិច្ចការកុងស៊ុល : មានមុខងារសម្របសម្រួលកិច្ចការកុងស៊ុល
- នាយកដ្ឋានកិច្ចការព្រំដែន : មានមុខងារសម្របសម្រួលកិច្ចការព្រំដែន។

## ជំពូកទី៧
## អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក

**មាត្រា១៩.-**

អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលើការងារនយោបាយ និងការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

**មាត្រា២០.-**

អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក មានភារកិច្ចដូចតទៅ៖

- ធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក
- សិក្សា ស្រាវជ្រាវ តាមដាន វិភាគ និងរាយការណ៍អំពីសភាពការណ៍នយោបាយ សន្តិសុខ វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្មនៅក្នុងប្រទេសនៃតំបន់អាស៊ី និងប៉ាស៊ីហ្វិក
- សហការជាមួយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ដើម្បីសិក្សា និងតាមដានសុពលភាពនៃកិច្ចព្រមព្រៀងទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក
- រៀបចំផែនការយុទ្ធសាស្ត្រនិងថវិកាសម្រាប់កិច្ចការសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក
- រៀបចំចំណុចពិភាក្សា និងជំនួយស្មារតីស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសនៅអាស៊ី និងប៉ាស៊ីហ្វិកជូនថ្នាក់ដឹកនាំ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ជាមួយស្ថានទូតបរទេសប្រចាំនៅកម្ពុជា
- សម្របសម្រួលការងារជាមួយស្ថានតំណាងកម្ពុជាប្រចាំនៅបណ្តាប្រទេសក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឲ្យ។

**មាត្រា២១.-**

អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក មាននាយកដ្ឋានចំណុះចំនួន០៣(បី)ជាសេនាធិការ៖

- នាយកដ្ឋានអាស៊ីអាគ្នេយ៍ : មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍
- នាយកដ្ឋានអាស៊ីកណ្តាល អាស៊ីខាងត្បូង និងអូសេអានី : មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេស ក្នុងតំបន់អាស៊ីកណ្តាល អាស៊ីខាងត្បូងនិងអូសេអានី
- នាយកដ្ឋានអាស៊ីបូព៌ា : មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេសក្នុងតំបន់អាស៊ីបូព៌ា។

## ជំពូកទី៨
## អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា

**មាត្រា២២.-**

អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលើការងារនយោបាយនិងការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា។

**មាត្រា២៣.-**

អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា មានភារកិច្ចដូចតទៅ៖

- ធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- សិក្សា ស្រាវជ្រាវ តាមដាន វិភាគ និងរាយការណ៍អំពីសភាពការណ៍នយោបាយ សន្តិសុខ វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្មនៅក្នុងប្រទេសនៃតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- សិក្សា និងតាមដានសុពលភាពនៃកិច្ចព្រមព្រៀងទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- រៀបចំផែនការយុទ្ធសាស្ត្រនិងថវិកាសម្រាប់កិច្ចការសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- រៀបចំចំណុចពិភាក្សា និងជំនួយស្មារតីស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសនៅក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា ជូនថ្នាក់ដឹកនាំ
- សម្របសម្រួលការងារជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ជាមួយស្ថានទូតបរទេសប្រចាំនៅកម្ពុជា

- សម្របសម្រួលការងារជាមួយស្ថានតំណាងរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបណ្ដាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា២៤.-**

អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា មាននាយកដ្ឋានចំណុះចំនួន០៣(បី)ជាសេនាធិការ៖

- នាយកដ្ឋានអឺរ៉ុប: មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេសនៅអឺរ៉ុប
- នាយកដ្ឋានអាមេរិក: មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេសនៅអាមេរិក
- នាយកដ្ឋានអាហ្វ្រិក-មជ្ឈិមបូព៌ា: មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេសនៅអាហ្វ្រិក-មជ្ឈិមបូព៌ា។

## ជំពូកទី៩
## អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

**មាត្រា២៥.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងបេសកកម្មលើកកម្ពស់ ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការនិងសម្របសម្រួលការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទាំងក្នុងកម្រិតអនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក ព្រមទាំង ការងារពាក់ព័ន្ធនឹងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៦.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការយុទ្ធសាស្ត្រ និងថវិកាសម្រាប់ការងារសហប្រតិបត្តិការអន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងលើកយោបល់លើការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានាក្នុងកម្រិត អនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក
- សម្របសម្រួលកិច្ចការសហប្រតិបត្តិការអន្តរជាតិលើគ្រប់វិស័យដែលមានជាអាទិ៍ នយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ពាណិជ្ជកម្ម វប្បធម៌ អប់រំ វិទ្យាសាស្ត្រ-បច្ចេកទេស សង្គមកិច្ច ទេសចរណ៍។ល។

- សម្របសម្រួលកិច្ចការអង្គការអន្តររដ្ឋាភិបាលនានានិងអង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក ដែលមានកិច្ចសហប្រតិបត្តិការជាមួយព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលនិងធ្វើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញការរៀបចំនិងការអនុវត្តផែនការសកម្មភាព និងគម្រោងពាក់ព័ន្ធនានារបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ អនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក
- គ្រប់គ្រងនិងសម្របសម្រួលការងារអង្គការមិនមែនរដ្ឋាភិបាលបរទេសនានា ដែលមានទីស្នាក់ការ និងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំចំណុចពិភាក្សា និងជំនួយស្មារតីជូនថ្នាក់ដឹកនាំ និងចូលរួមកិច្ចប្រជុំសំខាន់ៗដែលពាក់ព័ន្ធនឹងសហប្រតិបត្តិការអនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក ព្រមទាំងកិច្ចការពាក់ព័ន្ធនឹងអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិ
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន។

**មាត្រា២៧.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មាននាយកដ្ឋានចំណុះចំនួន០៥(ប្រាំ)ជាសេនាធិការៈ

- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិៈ មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល អនុតំបន់ តំបន់ អន្តរតំបន់ និងអង្គការពិភពលោកដែលពាក់ព័ន្ធ
- នាយកដ្ឋានសហប្រតិបត្តិការមេគង្គៈ មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការមេគង្គ
- នាយកដ្ឋានអង្គការសហប្រជាជាតិ : មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអង្គការសហប្រជាជាតិ
- នាយកដ្ឋានអង្គការអន្តរជាតិ : មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានទីស្នាក់ការនិងធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា
- នាយកដ្ឋានអង្គការហ្វ្រង់កូហ្វូនីៈមានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអង្គការហ្វ្រង់កូហ្វូនី។

## ជំពូកទី១០
## អគ្គាធិការដ្ឋាន

**មាត្រា២៨.-**

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិក្នុងបេសកកម្មធ្វើអធិការកិច្ចជាប្រចាំលើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិក និងមន្ត្រីរាជការក្នុងនិងក្រៅប្រទេស។

**មាត្រា២៩.-**

អគ្គាធិការដ្ឋាន មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការយុទ្ធសាស្ត្រ និងថវិកាសម្រាប់ការងារអធិការកិច្ច
- ធ្វើអធិការកិច្ចខ្ទទៅលើកិច្ចដំណើរការរដ្ឋបាល ហិរញ្ញវត្ថុ ការគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការរបស់ក្រសួង អង្គភាពក្រោមឱវាទ និងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- ចុះត្រួតពិនិត្យពាក្យបណ្តឹងតវ៉ានិងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ដែលទាក់ទងនឹងវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន។

**មាត្រា៣០.-**

អគ្គាធិការដ្ឋានមាននាយកដ្ឋានចំណុះចំនួន ០២(ពីរ) ជាសេនាធិការ៖

- នាយកដ្ឋានអធិការកិច្ចរដ្ឋបាលកណ្តាល: មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអធិការកិច្ចរដ្ឋបាលកណ្តាល
- នាយកដ្ឋានអធិការកិច្ចស្ថានតំណាងក្រៅប្រទេស: មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអធិការកិច្ចស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស។

## ជំពូកទី១១
## វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ

**មាត្រា៣១.-**

វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលើការងារអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវលើវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា៣២.-**

វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការយុទ្ធសាស្ត្រ និងថវិកា
- រៀបចំកម្មវិធីអប់រំ និងបណ្តុះបណ្តាលលើវិស័យការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ
- ចូលរួមចំណែកសិក្សាស្រាវជ្រាវ វាយតម្លៃស្ថានការណ៍ជាតិ និងពិភពលោក វិភាគយុទ្ធសាស្ត្រ និងផ្តល់យោបល់ក្នុងការរៀបចំគោលនយោបាយការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំកម្មវិធី បាឋកថា វេទិកាពិភាក្សា និងសិក្ខាសាលាពាក់ព័ន្ធនឹងកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចូលរួមចំណែករៀបចំឱ្យមានការប្រឡងវាស់កម្រិតសមត្ថភាពជំនាញការទូត និងការសិក្សាអន្តរជាតិ
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា ដើម្បីពង្រឹងការអប់រំ បណ្តុះបណ្តាល ស្រាវជ្រាវ និងផ្ទេរចំណេះដឹងលើវិស័យការទូត និងការសិក្សាអន្តរជាតិ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា៣៣.-**

វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិមាននាយកដ្ឋានចំណុះចំនួន ០២(ពីរ) ជាសេនាធិការ ៖

- នាយកដ្ឋានទំនាក់ទំនងការទូត : មានមុខងារសម្របសម្រួលការសិក្សាស្រាវជ្រាវកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សំដៅបណ្តុះបណ្តាលជំនាញការទូត
- នាយកដ្ឋានសិក្សាអន្តរជាតិ : មានមុខងារសម្របសម្រួលការសិក្សាស្រាវជ្រាវកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សំដៅបណ្តុះបណ្តាលជំនាញការសិក្សាអន្តរជាតិ។

## ជំពូកទី១២
## នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**មាត្រា ៣៤.-**

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការ

អន្តរជាតិ លើការងារគ្រប់គ្រង និងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងការគ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មាន និងឯកសារ ។

## ជំពូកទី១៣

## នាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ

**មាត្រា ៣៥.-**

នាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រ ជាសេនាធិការឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើការងារសម្របសម្រួលរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី១៤

## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៣៦.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លើការងារពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ តាមស្មារតីខ្លឹមសារនៃអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្ដាក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ។

## ជំពូកទី១៥

## ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

**មាត្រា៣៧.-**

ស្ថានឯកអគ្គរាជទូត ស្ថានតំណាង ឬ ស្ថានបេសកកម្មអចិន្ត្រៃយ៍នានាប្រចាំអង្គការតំបន់ និងអង្គការអន្តរជាតិ ត្រូវដឹកនាំដោយឯកអគ្គរាជទូតជាប្រធានបេសកកម្ម។

ការតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់បេសកកម្មឯកអគ្គរាជទូត ត្រូវស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា។

ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព គឺតំណាងឱ្យរាជរដ្ឋាភិបាលលើគ្រប់វិស័យ។

**មាត្រា៣៨.-**

ស្ថានអគ្គកុងស៊ុល ត្រូវដឹកនាំដោយអគ្គកុងស៊ុលជាប្រធានបេសកកម្ម។

ស្ថានកុងស៊ុល ត្រូវដឹកនាំដោយកុងស៊ុលជាប្រធានបេសកកម្ម។

អគ្គកុងស៊ុល ត្រូវជ្រើសរើសនិងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជូនប្រមុខរាជរដ្ឋាភិបាល។

កុងស៊ុល និងកុងស៊ុលកិត្តិយស ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី១៦
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា៣៩.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី១៧
## អវសានប្បញ្ញត្តិ

**មាត្រា៤០.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម៖

- អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- អនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ស្តីពីការបង្កើតនាយកដ្ឋានសហប្រតិបត្តិការមេគង្គ
- អនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០១ ស្តីពីការប៉ែបែកនាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក ជានាយកដ្ឋានអាស៊ីទី១ និងនាយកដ្ឋានអាស៊ីទី២។

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារៈកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៧០អនក្រ.បក
ចុះថ្ងៃទី២៧ខែ ឧសភា ឆ្នាំ២០១៦

**អង្គការលេខរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**



# ឧបសម្ព័ន្ធទី៣៖
## សេចក្តីសម្រេច ស្តីពី
## ការបង្កើតក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ: ៤៧១៨ កបទ.សអ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

### ប្រការ ១.-

ត្រូវបានបង្កើត ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច ដែលសរសេរជាអក្សរកាត់ថា **ក.ទ.ស.** សំដៅលើកកំពស់ និងជម្រុញវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ធុរកិច្ច ទេសចរណ៍ ការងារអប់រំ និងបច្ចេកវិទ្យា និងផ្សព្វផ្សាយលើកតម្កើង វប្បធម៌ ប្រពៃណី និងទំនៀមទំលាប់ខ្មែរនៅក្រៅប្រទេស ដើម្បីជានាបាននូវប្រភពកំណើនបន្ថែម តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។



អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

**ប្រការ២.-**

**ក.ឧ.ស.** មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| **១. ឯកឧត្តម ញឹម ខេមរា** | រដ្ឋលេខាធិការ | ប្រធាន |
| **២. ឯកឧត្តម ឈីវ យីស៊ាង** | រដ្ឋលេខាធិការ | អនុប្រធាន |
| **៣. ឯកឧត្តម សុខ សូកេន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| **៤. ឯកឧត្តម អ៊ុក សារុន** | អនុរដ្ឋលេខាធិការ | សមាជិក |
| **៥. ឯកឧត្តម ឈាង វណ្ណារិទ្ធ** | ទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| **៦. ឯកឧត្តម ណី សំអុល** | អគ្គនាយក នៃអគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈឹមបូព៌ា | សមាជិក |
| **៧. ឯកឧត្តម ថៃ ជុន** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិ | សមាជិក |
| **៨. ឯកឧត្តម ស៊ឹម វីរៈ** | អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ាន | សមាជិក |
| **៩. ឯកឧត្តម ថូ សំណាង** | អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុលនិងព្រំដែន | សមាជិក |
| **១០. ឯកឧត្តម ហ៊ុន សារឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក | សមាជិក |
| **១១. ឯកឧត្តម ទាន សំណាង** | ប្រធានវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ | សមាជិក |
| **១២. លោកជំទាវ ពេជ្រ ពុទ្ធិសាធបូព៌ានារី** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិកា |
| **១៣. ឯកឧត្តម ជីនបូរាណ ច័ន្ទបូរី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន | សមាជិក |
| **១៤. លោក លីវ សុផាវណ្ណារីន** | ជំនួយការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| **១៥. លោក សន ច័ន្ទរិទ្ធី** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ-គណនេយ្យ | សមាជិក |
| **១៦. លោក លឹម ហុកសេង** | ប្រធាននាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ | សមាជិក |
| **១៧.តំណាងក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍** | | សមាជិក |
| **១៨. គ្រប់ប្រធានស្ថានតំណាងកម្ពុជានៅបរទេស** | | សមាជិក |
| **១៩. លោក ចែម វណ្ណាវរឫទ្ធិ** | អនុប្រធានការិយាល័យ | លេខាធិការ |
| **២០. លោក ឧុឌ្ឍី វចន្សមនសិការ** | មន្ត្រី | លេខាធិការ |
| **២១. កញ្ញា សុខ សេរីវឌ្ឍនា** | មន្ត្រី | លេខាធិការ |

២

| | | |
|---|---|---|
| **២២. លោកស្រី អាង ម៉ូនីកា** | មន្ត្រី | លេខាធិការ |
| **២៣. លោកស្រី នាង ឡានីត** | ជំនួយការឯកឧត្តម ញឹម ខេមរា | លេខាធិការ |
| **២៤. កញ្ញា មាស សុជីនិត្យ** | ជំនួយការឯកឧត្តម ញឹម ខេមរា | លេខាធិការ |

**ប្រការ៣**.-

**គ.ទ.ស**. មានភារកិច្ច ដូចតទៅ៖

- ប្រមូលផ្តុំនូវគោលនយោបាយ និងសកម្មភាពដែលមានស្រាប់ ដើម្បីអនុវត្តការទូតសេដ្ឋកិច្ចឲ្យមានប្រសិទ្ធភាព ឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលបំណងគោលនយោបាយរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- សម្របសម្រួលកម្មវិធី និងធ្វើសកម្មភាពរួមគ្នាជាមួយក្រសួង/ស្ថាប័ន/ទីភ្នាក់ងារពាក់ព័ន្ធ និងផ្នែកឯកជន ដើម្បីការរៀបចំកម្មវិធីផ្សព្វផ្សាយទាក់ទាញវិនិយោគិន និងទេសចរណ៍ប្រកបដោយភាពប្រទាក់ក្រឡា
- បង្កើតក្របខ័ណ្ឌសកម្មភាព និងរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣
- ស្រាវជ្រាវ វិភាគទិន្នន័យ និងចងក្រងឯកសារ (ផ្ទាំងព័ត៌មាន និងជំនួយស្មារតី) ឲ្យមានសង្គតភាពដើម្បីផ្តល់ជូនអ្នកការទូតប្រើប្រាស់
- សហការជាមួយស្ថាប័នជាតិ/អន្តរជាតិរៀបចំកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សបំរើការងារការទូតសេដ្ឋកិច្ច
- ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តការទូតសេដ្ឋកិច្ច ព្រមទាំងធ្វើរបាយការណ៍ប្រចាំត្រីមាសនិងប្រចាំឆ្នាំជូនរដ្ឋមន្ត្រី
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី។

**ប្រការ៤**.-

**គ.ទ.ស**. មាននាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការដ្ឋាន សម្រាប់សម្របសម្រួលកិច្ចដំណើរការការងាររបស់ខ្លួន។

**ប្រការ៥**.-

**គ.ទ.ស**. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសម្រាប់ប្រតិបត្តិការការងាររបស់ខ្លួន។

**ប្រការ៦**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

៣

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ ប្រធានអង្គភាពក្រោមឱវាទក្រសួង និងសាមីខ្លួនដូចមានក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២០
**រដ្ឋមន្ត្រី**

**ប្រាក់ សុខុន**

<u>**កន្លែងទទួល:**</u>

- គ្រប់ថ្នាក់ដឹកនាំក្រសួង/ស្ថាប័នពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទ
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤៖
## សេចក្តីសម្រេច ស្តីពីការកែសម្រួល
## សមាសភាពក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ: ៧៥៤ កបទ.សអ

# សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលសមាសភាពក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

- យោងសេចក្ដីសម្រេចលេខ ២៧២ កបទ.សអ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការបង្កើតក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**ប្រការ១**.-

ត្រូវបានកែសម្រួល សមាសភាពនៃក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ចដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| **១. ឯកឧត្ដម ញឹម ខេមរា** | រដ្ឋលេខាធិការ | ប្រធាន |
| **២. ឯកឧត្ដម ឈីវ យីស៊ាង** | រដ្ឋលេខាធិការ | អនុប្រធាន |
| **៣. ឯកឧត្ដម សុខ សូកេន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| **៤. លោកជំទាវ ជ្រឹង បុទុមរង្សី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| **៥. ឯកឧត្ដម អ៊ឹក សារុន** | អនុរដ្ឋលេខាធិការ | សមាជិក |
| **៦. ឯកឧត្ដម ឈាង វណ្ណារិទ្ធ** | ទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| **៧. ឯកឧត្ដម ណើ សំអុល** | អគ្គនាយក នៃអគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា | សមាជិក |



អាសយដ្ឋាន: លេខ ៣ វិថី **សម្ដេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

| | | |
|---|---|---|
| **៨. ឯកឧត្តម ថៃ ជុន** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| **៩. ឯកឧត្តម ស៊ឹម វីរៈ** | អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ាន | សមាជិក |
| **១០. ឯកឧត្តម ថូ សំណាង** | អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុលនិងព្រំដែន | សមាជិក |
| **១១. ឯកឧត្តម ហ៊ីន សារឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក | សមាជិក |
| **១២. ឯកឧត្តម ជីនបូរាណា ច័ន្ទបូរី** | អគ្គនាយក នៃអគ្គនាយកដ្ឋានស្រាវជ្រាវ វិភាគ និងព្យាករណ៍ | សមាជិក |
| **១៣. ឯកឧត្តម ឆាន សំណាង** | ប្រធានវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ | សមាជិក |
| **១៤. លោកជំទាវ ពេជ្រ ពុទ្ធិសាធបូព៌ានារី** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិកា |
| **១៥. លោក លីវ សុផាណ្ណារើន** | ជំនួយការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| **១៦. លោក សន ច័ន្ទរិទ្ធី** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ-គណនេយ្យ | សមាជិក |
| **១៧. លោក លឹម ហុកសេង** | ប្រធាននាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ | សមាជិក |
| **១៨. គ្រប់ប្រធានស្ថានតំណាងកម្ពុជានៅបរទេស** | | សមាជិក |
| **១៩. លោក ចែម វណ្ណាវរឬទ្ធិ** | អនុប្រធានការិយាល័យ | លេខាធិការ |
| **២០. លោក ឌុឡារី វឌ្ឍមនសិការ** | មន្ត្រី | លេខាធិការ |
| **២១. លោកស្រី សុខ សេរីវឌ្ឍនា** | មន្ត្រី | លេខាធិការ |
| **២២. លោកស្រី អាង ម៉ូនីកា** | មន្ត្រី | លេខាធិការ |
| **២៣. លោកស្រី នាង ឡានីត** | មន្ត្រី | លេខាធិការ |
| **២៤. កញ្ញា មាស សុជីនិត្យ** | មន្ត្រី | លេខាធិការ |
| **២៥. លោក អួន វណ្ណាដា** | មន្ត្រី | លេខាធិការ |

**ប្រការ២.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ ប្រធានអង្គភាពក្រោមឱវាទក្រសួង និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ០២ រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ប្រាក់ សុខុន**

<u>កន្លែងទទួល៖</u>
- គ្រប់ថ្នាក់ដឹកនាំក្រសួង/ស្ថាប័នពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទ
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

# ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច

# Economic Diplomacy Coordination Group

---


បោះពុម្ពផ្សាយ ខែមករា ឆ្នាំ២០២១

Published in January 2021


Scan QR Code
to download
the documents
( Khmer & English )


អគារលេខ ៣, វិថីសម្តេច ហ៊ុន សែន,
សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន,
រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ ( +855 ) 23 214 441
ទូរសារ៖ ( +855 ) 23 216 141
អ៊ីម៉ែល៖ mfaic@mfaic.gov.kh
គេហទំព័រ៖ www.mfaic.gov.kh